# ព្រឹទ្ធសភា

# SENATE MAGAZINE

ទស្សនាវដ្តីប្រចាំខែសីហា




លេខ ២៦២ ឆ្នាំទី២២
ពុទ្ធសករាជ ២៥៦៦ គ្រិស្តសករាជ ២០២២

Issue 262 Volume 22
Before Christ 2566 Common Era 2022

# មាតិកា


## សកម្មភាពថ្នាក់ដឹកនាំ



- គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាប្រជុំពិនិត្យសម្រេចលើ របៀបវារៈចំនួន៥ .......... ១
- ព្រឹទ្ធសភាបើកសម័យប្រជុំលើកទី៩ នីតិកាលទី៤ ដើម្បីពិនិត្យហើយឱ្យយោបល់លើរបៀបវារៈចំនួន៥.......... ២
- សម្តេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យបេក្ខជនជ័យលាភីអាហារូបករណ៍សិក្សានៅប្រទេសជប៉ុន ចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍ ..........៦
- សម្តេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យប្រធានគណៈកម្មាធិការមជ្ឈិមរណសិរ្សមាតុភូមិវៀតណាម ចូលជួបសម្តែងការគួរសម ..........៩
- សម្តេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យលោកជំទាវប្រធានសមាគមមិត្តភាពវៀតណាម-កម្ពុជា ចូលជួបសម្តែងការគួរសម .......... ១១
- សម្តេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ចូលជួបសម្តែងការគួរសម .......... ១៤
- សម្តេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យឯកឧត្តមឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋអាមេនី ចូលជួបសម្តែងការគួរសម..... ១៦
- សម្តេចវិបុលសេនាភក្តី សាយ ឈុំ ទទួលជួបប្រធានគណៈទាក់ទងបរទេស នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម .......... ១៨
- ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញជាអធិបតីភាពក្នុងពិធីចុះអនុស្សរណៈ នៃការយោគយល់គ្នាស្តីពីកិច្ចព្រមព្រៀងផ្តល់ជំនួយមនុស្សធម៌ដល់ព្រឹទ្ធសភា..........២១
- ថ្នាក់ដឹកនាំព្រឹទ្ធសភាសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ..........២២

## សកម្មភាពគណៈកម្មការ



- គណៈកម្មការទី២ព្រឹទ្ធសភាចុះឈ្វេងយល់អំពីការពង្រឹងកិច្ចការរដ្ឋបាលឃុំ សង្កាត់ ក្រោយការបោះឆ្នោត នៅខេត្តព្រៃវែង .......... ២៥
- សាស្ត្រាចារ្យ និស្សិតសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តក្រចេះ ទស្សនកិច្ចសិក្សានៅព្រឹទ្ធសភា..........២៧
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ..........២៩
- ការងារទទួលពាក្យបណ្តឹង.......... ៣២
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស .......... ៣២
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨.......... ៣៣
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ .......... ៣១

## សកម្មភាពអគ្គលេខាធិការដ្ឋាន



- ឯកឧត្តម អ៊ុំ សារឹទ្ធ៖ បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ព្រឹទ្ធសភាលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែនទន់ភ្លន់ក្នុងសភាពការណ៍ចល័ត.........៤៥
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ .......... ៤៧



**អ្នកគ្រប់គ្រងទូទៅ**

ឯកឧត្តម អ៊ុំ សារឹទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**

ឯកឧត្តម លីម ប៊ុនហុក

ឯកឧត្តម កែវ ចាន់ណា

ឯកឧត្តម សុខ រិទ្ធី

ឯកឧត្តម ជួន ណា

ឯកឧត្តម គឹម ពិសិដ្ឋ

លោក ជួន សុខឌី

លោក ទេព មករា

លោក កុក វ៉ៃ

**អ្នកគ្រប់គ្រងផ្ទាល់**

លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**

ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**

លោក ជុំ ច័ន្ទរតនា

កញ្ញា សុខ សុជាតា


*ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញដឹកនាំបើកសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤។*

*ក្របក្រោយ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា អញ្ជើញថតរូបអនុស្សាវរីយជាមួយនឹងបេក្ខជន បេក្ខនារី ជ័យលាភីអាហារូបករណ៍សិក្សានៅប្រទេសជប៉ុន នៅវិមានព្រឹទ្ធសភា៕*


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

**ទូរស័ព្ទ: (855) 23 211441, 211442, 211443, ទូរសារ: (855) 23 211446**

**E-mail : oumsarith.sgsenate@gmail.com**

**Website: www.senate.gov.kh**

**www.elibrary.senate.gov.kh**

**Facebook: www.facebook.com/senateofcambodia**

# គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាប្រជុំពិនិត្យសម្រេចលើរបៀបវារៈចំនួន៥



*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៤ ខែសីហា ឆ្នាំ២០២២ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានបើកកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យ និងសម្រេចរបៀបវារៈសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤ រួមមាន៖

១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌ សុំដាក់សេចក្ដីព្រាងច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្មមាត្រា១៩ថ្មី (មួយ) មាត្រា៨៩ មាត្រា៩៨ថ្មី មាត្រា១០២ថ្មី មាត្រា១១៩ថ្មី(មួយ) និងមាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ថ្មី និងមាត្រា៤ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ។

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម សុំដាក់សេចក្ដីព្រាងច្បាប់ស្ដីពី ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

៣-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម សុំដាក់សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើ៖

៣.១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃតំបន់រដ្ឋបាលពិសេសម៉ាកាវ នៃសាធារណរដ្ឋប្រជាមានិតចិន ស្ដីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ

៣.២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋតួកគី ស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

៤-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់សុំដាក់សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាស្ដីពី ជំនួយក្នុងករណីមានគ្រោះមហន្តរាយនុយក្លេអ៊ែរ ឬគ្រោះអាសន្នវិទ្យុសកម្ម។

៥- កំណត់ កាលបរិច្ឆេទ និងសមាសភាពលេខាធិការសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤។

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានកំណត់យកថ្ងៃសុក្រ ទី៥ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង៨:០០នាទីព្រឹក ដើម្បីបើកសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីស្ដាប់របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ ស្ដីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំព្រឹទ្ធសភាលើកទី៨ និងលើកទី៩ នីតិកាលទី៤ និងពិនិត្យហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ទាំងបួនខាងលើ៕

(អត្ថបទ៖ អ៊ុក ប៉ូលីន និងរូបភាព៖ គង់ យ៉ារីន)



*ទិដ្ឋភាពកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# ព្រឹទ្ធសភាបើកសម័យប្រជុំលើកទី៩ នីតិកាលទី៤ ដើម្បីពិនិត្យហើយឱ្យយោបល់លើរបៀបវារៈចំនួន៥




*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ដឹកនាំបើកសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤*

យោងស្មារតីនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា កាលពីថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបើកសម័យប្រជុំលើកទី៩ នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃសុក្រ ទី៥ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង៨:០០នាទី ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៥៧រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួន៥ ដូចខាងក្រោម៖

**របៀបវារៈទី១៖ស្ដាប់របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ ស្ដីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤។**

ក្នុងអំឡុងពេលចន្លោះសម័យប្រជុំព្រឹទ្ធសភា ថ្នាក់ដឹកនាំគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការ ក្រុមភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា និងសមាជិក សមាជិកាព្រឹទ្ធសភា បានខិតខំបំពេញភារកិច្ចរៀងៗខ្លួន ហើយសម្រេចបានលទ្ធផលផ្លែផ្កាជាគុណប្រយោជន៍ដល់ជាតិ និងប្រជាពលរដ្ឋ។

សកម្មភាពលេចធ្លោ គឺការយកចិត្តទុកដាក់ធ្វើសកម្មភាពឆ្ពោះទៅកាន់មូលដ្ឋាន តាមរយៈការចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ និងការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ដល់ប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត ដោះស្រាយសំណូមពរ និងបញ្ហាប្រឈមនានា ព្រមទាំងការចូលរួមចំណែកដល់ការអភិវឌ្ឍលើគ្រប់វិស័យនៅថ្នាក់ក្រោមជាតិ។ គណៈកម្មការទាំង១០ និងក្រុមនានា ដែលជាសេនា-



*ទិដ្ឋភាពសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤*



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ឡើងអានរបាយការណ៍សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩*

ធិការរបស់ព្រឹទ្ធសភា បានចុះជួបពិភាក្សាការងារជាមួយក្រសួង-ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីសិក្សាឈ្វេងយល់អំពីវឌ្ឍនភាពការងារតាមវិស័យ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការល្អជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ជាពិសេសជាមួយសមាជិកក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ ដែលទើបបានជាប់ឆ្នោតកន្លងទៅថ្មីៗនេះ។

ព្រឹទ្ធសភាសូមសម្ដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រដ៏ថ្លៃថ្លាពីគ្រប់មជ្ឈដ្ឋានដៃគូនានា និងគ្រប់ស្ថាប័នជាតិ ដែលញ៉ាំងឱ្យព្រឹទ្ធសភាដំណើរការទៅមុខដោយរលូន។

**របៀបវារៈទី២៖ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ធម្មនុញ្ញស្ដីពី វិសោធនកម្មមាត្រា១៩ថ្មី (មួយ) មាត្រា៨៩ មាត្រា៩៨ថ្មី មាត្រា១០២ថ្មី មាត្រា១១៩ថ្មី (មួយ) និងមាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ថ្មី និងមាត្រា៤ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ។**

សេចក្ដីព្រាងច្បាប់នេះ រៀបចំឡើងក្នុងគោលបំណងសំដៅធានាឱ្យស្ថាប័នកំពូលរបស់ជាតិ ជាពិសេសអំណាចនីតិប្រតិបត្តិដែលមានបេសកកម្មចម្បងក្នុងការដឹកនាំការងារទូទៅរបស់រដ្ឋបានដំណើរការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយនិរន្តរភាពនៅគ្រប់កាលៈទេសៈ ហើយធានាការពារ និងថែរក្សាបាននូវសន្តិភាព សន្តិសុខសង្គម សណ្ដាប់ធ្នាប់សាធារណៈ និងស្ថិរភាពនយោបាយរបស់ប្រទេសជាតិនៅគ្រប់កាលៈទេសៈ ដើម្បីជាគ្រឹះសម្រាប់ការអភិវឌ្ឍប្រទេសលើគ្រប់វិស័យ និងសេចក្ដីសុខសាន្តរបស់ប្រជាជនកម្ពុជា។

សេចក្ដីព្រាងច្បាប់ធម្មនុញ្ញស្ដីពី វិសោធនកម្មនេះ តាក់តែងឡើងយ៉ាងលម្អិត ធានាបាននូវភាពត្រឹមត្រូវ នៃការគោរពគោលការណ៍គ្រឹះនៃរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ដែលជារបបដឹកនាំប្រទេសបែបសភានិយម ព្រមទាំងជាការលើកកម្ពស់នូវគោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ដែលប្រជាជនកម្ពុជាបង្ហាញឆន្ទៈ និងប្រើសិទ្ធិអំណាចរបស់ខ្លួន តាមរយៈការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលប្រព្រឹត្តទៅរៀងរាល់៥ឆ្នាំម្ដង ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ព្រមទាំងច្បាប់ និងបទដ្ឋានគតិយុត្តជាធរមានរបស់ជាតិ។

សេចក្ដីព្រាងច្បាប់នេះ ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមជាលើកដំបូងចំនួន១០៥ សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី



*ឯកឧត្តម អ៊ុក ប៊ុនឈឿន ឡើងអានរបាយការណ៍ពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ ក្នុងរបៀបវារៈទី២*



*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឡើងការពារសេចក្ដីព្រាងច្បាប់*

២៨ ខែកក្កដា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី ៧ នីតិកាលទី៦។

ក្រោយពីសមាជិកព្រឹទ្ធសភាចំនួន២រូប បានឡើងមានយោបល់រួចមក ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកស្ដីទីការគណៈរដ្ឋមន្ត្រី បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្ដីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៥៧សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

**របៀបវារៈទី៣ៈពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។**

សេចក្ដីព្រាងច្បាប់នេះ ត្រូវបានតាក់តែងឡើងក្នុងគោលបំណងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលជាចំណូលថវិកាជាតិ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងសង្គតិភាព ដោយកំណត់ក្របខ័ណ្ឌច្បាប់ ស្ថាប័នជាគោល យន្តការ វិធាន និងនីតិវិធី នៃការគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ សំដៅរួមចំណែកបម្រើឧត្តមប្រយោជន៍នៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច នៃព្រះរាជាណាចក្រកម្ពុជា ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ២០១៤-២០១៨ និងយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល។

សេចក្ដីព្រាងច្បាប់នេះតាក់តែងឡើងមាន១២ជំពូក និង ១០១មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមជាលើកដំបូងចំនួន៩៦សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៦។



ឯកឧត្តម ជា ជេដ្ឋ ឡើងអានរបាយការណ៍ពិនិត្យសិក្សា លើសេចក្ដីព្រាងច្បាប់ ក្នុងរបៀបវារៈទី៣ និងទី៤



ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឡើងការពារសេចក្ដីព្រាងច្បាប់

ក្រោយពីសមាជិកព្រឹទ្ធសភាចំនួន២រូប បានឡើងមានយោបល់រួចមក ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្ដីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៥៧សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

**របៀបវារៈទី៤ៈ ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើៈ**

**១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃតំបន់រដ្ឋបាលពិសេសម៉ាកាវ នៃសាធារណរដ្ឋប្រជាមានិតចិនស្ដីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ**

**២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋតួកគី ស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។**

សេចក្ដីព្រាងច្បាប់នេះ ពិតជាមានសារសំខាន់ ដោយកម្ពុជានឹងទទួលបានការទាក់ទាញ និងការសម្រួលការវិនិយោគ និងពាណិជ្ជកម្មអន្តរជាតិ ព្រមទាំងទប់ស្កាត់ និងបង្ក្រាបការគេចវេះពន្ធ ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ។

សេចក្ដីព្រាងច្បាប់នេះតាក់តែងឡើងមាន២មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមជាលើកដំបូងចំនួន៩១សំឡេង នៃចំនួនសមាជិករដ្ឋសភា

ទាំងមូល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៦។

ក្រោយពីសមាជិកព្រឹទ្ធសភាចំនួន១រូប បានឡើងមានយោបល់រួចមក ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៥៧សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។



*ឯកឧត្តម គង់ សារាជ ឡើងអានរបាយការណ៍ពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ក្នុងរបៀបវារៈទី៥*

**របៀបវារៈទី៥៖ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាស្តីពីជំនួយក្នុងករណីមានគ្រោះមហន្តរាយនុយក្លេអ៊ែរ ឬគ្រោះអាសន្នវិទ្យុសកម្ម។**

សេចក្តីព្រាងច្បាប់នេះ នឹងផ្តល់ឱកាសឱ្យកម្ពុជា អាចទទួលបានជំនួយបច្ចេកទេសជាឧបករណ៍ សម្ភារ និងថវិកាក្នុងករណីមានគ្រោះថ្នាក់ណាមួយកើតឡើងជាយថាហេតុនៅក្នុងកម្ពុជា ឬនៅក្នុងប្រទេសក្បែរខាងកម្ពុជា ឬប្រទេសក្នុងតំបន់ណាមួយ ដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់កម្ពុជា ដើម្បីធានាថាមានការទទួលខុសត្រូវលើផលវិបាកពីការសាយភាយសារធាតុវិទ្យុសកម្មមកលើបរិយាកាស និងបរិស្ថានរបស់កម្ពុជា។

សេចក្តីព្រាងច្បាប់នេះតាក់តែងឡើងមាន២មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមជាលើកដំបូងចំនួន៩១សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៦។



*ឯកឧត្តម ស៊ុយ សែម ឡើងការពារសេចក្តីព្រាងច្បាប់*

ក្រោយពីសមាជិកព្រឹទ្ធសភាចំនួន១រូប បានឡើងមានយោបល់រួចមក ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៥៧សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

(អត្ថបទ៖ ទេព មករា និងរូបភាព៖ គង់ យ៉ារីន)





*ទិដ្ឋភាពសមាជិក សមាជិកាព្រឹទ្ធសភាលើកដៃអនុម័តច្បាប់*

# សម្ដេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យបេក្ខជនជ័យលាភីអាហារូបករណ៍ សិក្សានៅប្រទេសជប៉ុន ចូលជួបសម្ដែងការគួរសម និងទទួលអនុសាសន៍



*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៨ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង៩:០០នាទី នៅវិមានព្រឹទ្ធសភា សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យបេក្ខជន បេក្ខនារី ជ័យលាភីអាហារូបករណ៍សិក្សានៅប្រទេសជប៉ុនសម្រាប់អភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជាហៅកាត់ថា JDS (Japanese Scholarship For Human Resource Development) ចំនួន២៤នាក់ ដែលនឹងត្រូវទៅសិក្សានៅប្រទេសជប៉ុន សម្រាប់ឆ្នាំសិក្សា២០២២-២០២៣ ចូលជួបសម្ដែងការគួរសម ដើម្បីទទួលអនុសាសន៍ណែនាំ។

កញ្ញា **សៅ សម្ផស្ស** មន្ត្រីរាជការ នៃក្រសួងបរិស្ថាន តំណាងឱ្យក្រុមនិស្សិត បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដែលបានចំណាយពេលវេលាដ៏មានតម្លៃអនុញ្ញាតឱ្យបេក្ខជន បេក្ខនារី ជ័យលាភីអាហារូបករណ៍អភិវឌ្ឍធនធានមនុស្សនៅកម្ពុជា ចូលជួបសម្ដែងការគួរសម និងទទួលអនុសាសន៍។

កញ្ញា **សៅ សម្ផស្ស** បានជម្រាបជូនសម្ដេចប្រធានព្រឹទ្ធសភា អំពីសមាសភាពបេក្ខជន បេក្ខនារីទាំង២៤នាក់ ដែលជាមន្ត្រីរាជការបម្រើការងារនៅតាមបណ្ដាក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលបានប្រឡងជាប់អាហារូបករណ៍ទៅសិក្សានៅប្រទេសជប៉ុន ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សិក្សារយៈពេល២ឆ្នាំ ឆ្នាំសិក្សា ២០២២-២០២៣ លើជំនាញ៖ អភិវឌ្ឍន៍រដ្ឋបាលសាធារណៈ សេដ្ឋកិច្ចបច្ចេក-





*ទិដ្ឋភាពក្នុងពិធីជួបសម្ដែងការគួរសម*



*ទិដ្ឋភាពក្នុងពិធីជួបសម្ដែងការគួរសម*

វិទ្យា នីតិសាស្ត្រ ទំនាក់ទំនងអន្តរជាតិ គុណភាពនៃការអប់រំ វិស័យសុខាភិបាល វិស័យទឹកស្អាត ពង្រឹងវិស័យជនបទ ពង្រឹងវិស័យកសិកម្ម និងជំនាញអភិបាលកិច្ច។

ក្នុងនាមព្រឹទ្ធសភា និងក្នុងនាមសម្ដេចផ្ទាល់ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** បានសម្ដែងនូវការស្វាគមន៍ និងអបអរសាទរចំពោះក្មួយៗដែលជាបេក្ខជន បេក្ខនារី ជ័យលាភីអាហារូបករណ៍ ដែលត្រូវទៅសិក្សានៅប្រទេសជប៉ុន។

សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្មួយៗដែលជាមន្ត្រីរាជការតាមក្រសួង ស្ថាប័ននានា បានខិតខំធ្វើការផង ខិតខំរៀនសូត្របន្ថែមផងរហូតសម្រេចបាននូវជ័យលាភីអាហារូបករណ៍នៃប្រទេសជប៉ុន។ នេះមិនគ្រាន់តែជាមោទកភាព និងកិត្តិយសសម្រាប់ផ្ទាល់ខ្លួនរបស់ក្មួយៗទាំងអស់តែប៉ុណ្ណោះទេ ប៉ុន្តែជាកិត្តិយសសម្រាប់គ្រួសារក្មួយៗ ស្ថាប័នដែលបំពេញការងារ សង្គមជាតិ និងប្រទេសជាតិផងដែរ។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ដូចក្មួយៗទាំងអស់បានជ្រាបហើយថា ជាង២ឆ្នាំកន្លងទៅនេះ កម្ពុជាយើងក៏ដូចជាបណ្ដាប្រទេសទាំងអស់នៅលើពិភពលោកទាំងមូល សុទ្ធតែត្រូវបានរងគ្រោះនូវមហន្តរាយយ៉ាងធ្ងន់ធ្ងរពីជំងឺដ៏កាចសាហាវកូវីដ-១៩។ នៅកម្ពុជាយើង រាជរដ្ឋាភិបាលដែលដឹកនាំដោយសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាទិញវ៉ាក់សាំង និងទទួលជំនួយវ៉ាក់សាំងពីប្រទេសនានា មកចាក់ជូនប្រជាជនគ្រប់រូបដោយគ្មានការរើសអើង និងមិនគិតថ្លៃ។ ប្រការនេះបានធ្វើឱ្យកម្ពុជាយើងក្លាយជាប្រទេសដែលគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩ បានយ៉ាងល្អប្រសើរ។ ទោះបីជាយ៉ាងនេះក្ដី ការចាក់វ៉ាក់សាំងទាំងដូសមូលដ្ឋាន ដូសជំរុញទី៣ ទី៤ និងទី៥ និងការចាក់វ៉ាក់សាំងជូនដល់កុមារចាប់ពីអាយុ៣ឆ្នាំឡើង ត្រូវបានធ្វើជាបន្តបន្ទាប់។ ដោយការគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩បានយ៉ាងល្អដូចនេះ ទើបកម្ពុជាយើងត្រូវបានវាយតម្លៃថា ជាប្រទេសឈានមុខគេនៅលើពិភពលោកក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ រាជរដ្ឋាភិបាលបានបើកប្រទេសឡើងវិញលើគ្រប់វិស័យ កាលពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១។ តាមការព្យាករណ៍របស់ធនាគារពិភពលោក កម្ពុជាអាចសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០២២ ប្រមាណ៤,៥% និងឆ្នាំ២០២៣ ប្រមាណជា ៥,៨%។ ជាមួយនឹងការគ្រប់គ្រងការរីករាលដាល នៃជំងឺកូវីដ-១៩បានល្អ រាជរដ្ឋាភិបាលធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច រក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជនផ្សារភ្ជាប់ជាមួយនឹងការអនុវត្តយុទ្ធសាស្ត្រ និងកម្មវិធីរស់នៅជាមួយកូវីដ-១៩តាមគន្លងប្រក្រតីភាពថ្មីឆ្នាំ២០២១-២០២៣ ឱ្យសម្រេចបានលទ្ធផលយ៉ាងល្អប្រសើរ។

ក្នុងបរិបទជំងឺកូវីដ-១៩ វិបត្តិជំងឺកូវីដ-១៩ ការប្រកួតប្រជែងខាងភូមិសាស្ត្រនយោបាយរវាងមហាអំណាច និងឥទ្ធិពលនៃសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែន បច្ចុប្បន្ននេះកម្ពុជាយើងនៅតែរក្សាបានសន្តិភាព ឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីយ៉ាងគត់មត់។

លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ត្រូវបានស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងប្រជាជនយើងគោរព និងអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់។ ការបោះឆ្នោតកាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២កន្លងទៅនេះ បានប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិភាព គ្មានអំពើហិង្សា គ្មានការគំរាមកំហែង មានលក្ខណៈសេរី និងយុត្តិធម៌ដែលទាំងអស់គ្នាអាចទទួលយកបាន។ លទ្ធផលនៃការបោះឆ្នោតបានបង្ហាញច្បាស់ថា ប្រជាជនកម្ពុជាភាគច្រើនលើសលុបដែលមិនគ្រាន់តែបោះឆ្នោតសម្តែងការជឿទុកចិត្តចំពោះការដឹកនាំរបស់រាជរដ្ឋាភិបាលបច្ចុប្បន្នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប៉ុណ្ណោះទេ គឺនៅបានសម្តែងឱ្យឃើញនូវការគាំទ្រដល់សន្តិភាព ស្ថិរភាព ព្រមទាំងការអភិវឌ្ឍ និងគាំទ្រយ៉ាងពេញទំហឹងចំពោះការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ជំនឿដ៏រឹងមាំដែលមិនអាចថមថយបាននេះ នឹងស្ថិតនៅជានិច្ចជាមួយនឹងការដឹកនាំ និងគ្រប់ការបោះឆ្នោតនៅពេលអនាគតថែមទៀត។

សម្តេចប្រធានព្រឹទ្ធសភាបានណែនាំដល់ក្មួយៗទាំងអស់ក្នុងរយៈពេលរៀនសូត្រនៅប្រទេសជប៉ុនត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានល្អនូវបញ្ហាមួយចំនួនដូចជាៈគោរព និងអនុវត្តឱ្យបានម៉ឺងម៉ាត់នូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងអស់របស់ប្រទេសសាមី ព្រមទាំងបទបញ្ជា និងវិន័យរបស់សាលា។ កសាងទំនាក់ទំនងល្អជានិច្ចជាមួយនឹងគណៈដឹកនាំសាលា សាស្ត្រាចារ្យ បុគ្គលិកសិក្សា និងមិត្តភក្តិនៅក្នុងសាលាទាំងអស់ ទាំងជនជាតិជប៉ុន ទាំងនិស្សិតបរទេស។ រក្សាប្រពៃណី ទំនៀមទម្លាប់ដ៏ល្អរបស់ខ្មែរយើងដែលជាប្រទេសមានអារ្យធម៌តាំងពីយូរលង់មកហើយ។ រក្សាឱ្យបានល្អនូវទំនាក់ទំនងជាមួយនឹងអាជ្ញាធរសាធារណៈ និងប្រជាជនជប៉ុន។ ខិតខំផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រ ប្រពៃណី វប្បធម៌ សក្តានុពលនៃការវិនិយោគ និងវិស័យទេសចរណ៍ ព្រមទាំងសភាពការណ៍ និងសមិទ្ធផលរបស់សង្គមជាតិយើង ជូនប្រជាជនជប៉ុនក៏ដូចជាមិត្តភក្តិនៅក្នុងសាលាដើម្បីបានជ្រាបច្បាស់អំពីសភាពការណ៍ពិតនៅកម្ពុជា។ ខិតខំធ្វើទំនាក់ទំនងជាមួយនឹងបងប្អូនខ្មែរដែលរស់នៅ និងធ្វើការងារនៅប្រទេសជប៉ុន ដើម្បីផ្សព្វផ្សាយជូននូវព័ត៌មានពិតអំពីប្រជាជន និងប្រទេសជាតិយើង សំដៅឱ្យបងប្អូនខ្មែរយើងនៅទីនោះបានជ្រាបអំពីការពិតរបស់ប្រទេសយើង។ ជាពិសេសសូមខិតខំថែរក្សាសាមគ្គីភាពក្នុងចំណោមជ័យលាភីអាហារូបករណ៍ទាំងអស់ ដែលត្រូវទៅរៀននៅប្រទេសជប៉ុនក្នុងជំនាន់ជាមួយគ្នា តាមសុភាសិតបុរាណរបស់ខ្មែរយើង "នៅផ្ទះម្តាយទីទៃ ទៅព្រៃម្តាយតែមួយ"។ ក្មួយៗទាំងអស់ត្រូវប្តេជ្ញាចិត្តខ្ពស់ ខិតខំរៀនសូត្រឱ្យទទួលបាននូវនិទ្ទេសខ្ពស់គ្រប់ៗគ្នា។ ប្រទេសជាតិ និងប្រជាជនរង់ចាំក្មួយៗទាំងអស់រៀនបានចប់ប្រកបដោយជោគជ័យ ហើយវិលត្រឡប់មកកាន់មាតុភូមិវិញ ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិឆ្ពោះទៅកាន់ភាពសម្បូររុងរឿង និងសុភមង្គលនាពេលអនាគត៕

(អត្ថបទ៖ វង់ សុជាតិ និងរូបភាព៖ គង់ យ៉ារីន)



*សម្តេចប្រធានព្រឹទ្ធសភា ប្រគល់វត្ថុអនុស្សាវរីយ៍ដល់តំណាងបេក្ខជនអាហារូបករណ៍*

# សម្តេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យប្រធានគណៈកម្មាធិការមជ្ឈិមរណសិរ្សមាតុភូមិវៀតណាម ចូលជួបសម្តែងការគួរសម



*ឯកឧត្តម ដុ វ៉ាន់ចៀន និងសម្តេចវិបុលសេនាភក្តី សាយ ឈុំ*

នារសៀលថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ១៦:០០នាទី សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម **ដុ វ៉ាន់ចៀន** គណៈលេខាមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម និងជាប្រធានគណៈកម្មាធិការមជ្ឈិមរណសិរ្សមាតុភូមិវៀតណាម ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។

ក្នុងនាមព្រឹទ្ធសភា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវសេចក្តីរីករាយ និងសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម **ដុ វ៉ាន់ចៀន** និងគណៈប្រតិភូ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។ សម្តេចជឿជាក់ថា ដំណើរទស្សនកិច្ចរបស់ឯកឧត្តម និងគណៈប្រតិភូនៅកម្ពុជា នឹងរួមចំណែកពូនជ្រំ និងលើកកម្ពស់ទំនាក់ទំនងដ៏ល្អរវាងប្រទេស និងប្រជាជន នៃប្រទេសទាំងពីរឱ្យកាន់តែរឹងមាំថែមទៀត។

ក្នុងឱកាសនោះ ឯកឧត្តម **ដុ វ៉ាន់ចៀន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចប្រធានព្រឹទ្ធសភា ដែលបានចំណាយពេលវេលាដ៏មានតម្លៃទទួលជួបគណៈប្រតិភូ។ ឯកឧត្តមបានជម្រាបថា នេះគឺជាលើកទី១ហើយ ដែលឯកឧត្តមបានមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមបានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើនលើគ្រប់វិស័យយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជា។ ឆ្លៀតក្នុងឱកាសនោះ ឯកឧត្តមក៏បានពាំនាំនូវការសួរសុខទុក្ខដ៏កក់ក្តៅពីឯកឧត្តមប្រធានរដ្ឋសភាវៀតណាមជូនចំពោះសម្តេចប្រធានព្រឹទ្ធសភាផងដែរ។

ឯកឧត្តម **ដុ វ៉ាន់ចៀន** បានជម្រាបជូនសម្តេចប្រធានព្រឹទ្ធសភាជ្រាបថា ក្នុងឱកាសខួបអនុស្សាវរីយលើកទី៥៥ នៃការបង្កើតទំនាក់ទំនងការទូតកម្ពុជា-វៀតណាម ឯកឧត្តមបានដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជានាពេលនេះ ក្នុងគោលបំណងដើម្បីពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងរណសិរ្សនៃប្រទេសទាំងពីរ ដែលមានតួនាទីសំខាន់សម្រាប់ឃោសនាអប់រំអំពីសមិទ្ធផលរួមនៃប្រទេសទាំងពីរ សម្រាប់ទុកឱ្យកូនចៅជំនាន់ក្រោយបានឃ្លេងយល់ ដឹង និងពូនជ្រំបន្ថែមទៀតនាពេលអនាគត។

ឯកឧត្តម **ដុ វ៉ាន់ចៀន** បានសម្តែងនូវសេចក្តីរីករាយ





*ទិដ្ឋភាពក្នុងពិធីជំនួបសម្តែងការគួរសម*

ដោយមើលឃើញទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកាន់តែល្អប្រសើរ។ ឯកឧត្តមមានជំនឿជឿជាក់ថា ប្រទេសទាំងពីរខិតខំប្រឹងប្រែងកសាងខ្សែបន្ទាត់ព្រំដែនប្រកបដោយការអភិវឌ្ឍ និងមានកិច្ចសហប្រតិបត្តិការល្អប្រពៃ។ ក្នុងសម័យកាលដែលមានសន្តិភាព ប្រទេសទាំងពីរនឹងបន្តពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អនេះ ឱ្យបានកាន់តែរឹងមាំបន្តបន្ទាប់ថែមទៀត។ រណសិរ្សមាតុភូមិវៀតណាមនឹងខិតខំប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយចិត្ត ដើម្បីបង្កើនកិច្ចសហការល្អជាមួយនឹងប្រជាជន និងថ្នាក់ដឹកនាំកម្ពុជា។

សម្ដេចប្រធានព្រឹទ្ធសភាបានវាយតម្លៃខ្ពស់ចំពោះដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៅព្រះរាជាណាចក្រកម្ពុជា ស្របពេលដែលប្រទេសទាំងពីរ ប្រារព្ធខួបអនុស្សាវរីយលើកទី៥៥ នៃការបង្កើតទំនាក់ទំនងការទូត និងជាឆ្នាំមិត្តភាពកម្ពុជា-វៀតណាម។ ប្រទេសទាំងពីរបានរៀបចំកម្មវិធីសកម្មភាពជាច្រើន ដើម្បីអបអរសាទរឆ្នាំជាប្រវត្តិសាស្ត្រនេះ រួមមានការផ្លាស់ប្ដូរដំណើរទស្សនកិច្ចរវាងថ្នាក់ដឹកនាំមន្ត្រីតាមក្រសួង ស្ថាប័ននានា ក៏ដូចជាមន្ត្រីនៅតាមមូលដ្ឋានផងដែរ។ ក្នុងរយៈពេល៥៥ឆ្នាំកន្លងទៅនេះ ប្រជាជននៃប្រទេសទាំងពីរបានឆ្លងកាត់នូវដំណាក់កាលជាប្រវត្តិសាស្ត្រជាច្រើន ដោយបានជួយគាំទ្រគ្នាទៅវិញទៅមកដើម្បីបុព្វហេតុឯករាជ្យ អធិបតេយ្យភាព បូរណភាព និងការអភិវឌ្ឍ។ ប្រទេសទាំងពីរត្រូវតែខិតខំពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការនេះ ឱ្យកាន់តែរឹងមាំខ្លាំងក្លាថែមទៀត ដើម្បីទុកជាមរតកសម្រាប់កូនចៅទាំងជំនាន់នេះ និងជំនាន់ក្រោយៗទៀត។

សម្ដេចប្រធានព្រឹទ្ធសភាបានវាយតម្លៃខ្ពស់ និងមានសេចក្ដីពេញចិត្តជាខ្លាំងចំពោះចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេស និងប្រជាជនទាំងពីរ ដែលបន្តរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ កាន់តែស៊ីជម្រៅមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងរឹងមាំយូរអង្វែង។ ជាមួយគ្នានោះ សម្ដេចបានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងរណសិរ្ស នៃប្រទេសទាំងពីរ ដែលបានរួមចំណែកដ៏ខ្លាំងក្លាក្នុងការឃោសនាអប់រំអំពីសមិទ្ធផលជូនប្រជាជននៃប្រទេសទាំងពីរ ក៏ដូចជាការរួមចំណែកដ៏ខ្លាំងក្លាក្នុងការពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព សាមគ្គីភាព និងសហប្រតិបត្តិការរវាងប្រទេសទាំងពីរក្នុងគ្រប់ស្ថានភាព និងគ្រប់កាលៈទេសៈ។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ព្រឹទ្ធសភាកម្ពុជាមានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អជាមួយនឹងរដ្ឋសភាវៀតណាម ទាំងក្នុងក្របខ័ណ្ឌ នៃកិច្ចសហប្រតិបត្តិការទ្វេភាគី និងនៅលើឆាកអន្តរជាតិ ដូចជា នៅក្របខ័ណ្ឌ IPU, AIPA, APF, APPF និងCLV ជាដើម។

ក្នុងនាមប្រជាជនកម្ពុជា សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវការដឹងគុណចំពោះកងទ័ព ប្រជាជន និងបក្សកុម្មុយនីស្តវៀតណាម ដែលតែងតែជួយគាំទ្រដល់បុព្វហេតុដ៏ត្រឹមត្រូវ យុត្តិធម៌របស់ប្រជាជនកម្ពុជាក្នុងគ្រប់ដំណាក់កាលទាំងអស់។

តាមរយៈគណៈប្រតិភូ សម្ដេចប្រធានព្រឹទ្ធសភាបានផ្ដាំផ្ញើសួរសុខទុក្ខដោយសេចក្ដីនឹករលឹក និងសេចក្ដីគោរពស្រឡាញ់ដ៏ស្មោះស្ម័គ្រជូនឯកឧត្ដមប្រធានរដ្ឋសភាវៀតណាម និងថ្នាក់ដឹកនាំជាន់ខ្ពស់វៀតណាមទាំងអស់។

សម្ដេចប្រធានព្រឹទ្ធសភាបញ្ជាក់ថា ប្រទេសកម្ពុជាចាត់ទុកវៀតណាម គឺជាមិត្តល្អ ជាបងប្អូនល្អ ជាអ្នកជិតខាងល្អ និងជាដៃគូល្អ តាមពាក្យស្លោក “ភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ស្ថិរភាពយូរអង្វែង”។

សម្ដេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរគណៈប្រតិភូមានសុខភាពល្អ និងដំណើរទស្សនកិច្ចនៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជាប្រកបដោយជោគជ័យ៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



ឯកឧត្តម ដុ វ៉ាន់ចៀន ថតរូបអនុស្សាវរីយជាមួយសម្ដេចប្រធានព្រឹទ្ធសភា

# សម្ដេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យលោកជំទាវប្រធានសមាគមមិត្តភាពវៀតណាម-កម្ពុជា ចូលជួបសម្ដែងការគួរសម



*លោកជំទាវ ង្វៀន ធីថាញ់ និងសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ*

នារសៀលថ្ងៃទី២ ខែសីហា ឆ្នាំ២០២២ នៅវិមានព្រឹទ្ធសភា វេលាម៉ោង១៤:០០នាទី សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យលោកជំទាវ **ង្វៀន ធីថាញ់** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ នៃរដ្ឋសភា និងជាប្រធានសមាគមមិត្តភាពវៀតណាម-កម្ពុជា ចូលជួបសម្ដែងការគួរសម ក្នុងឱកាសដែលលោកជំទាវ និងគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។

សម្ដេចប្រធានព្រឹទ្ធសភាជឿជាក់ថា ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៅកម្ពុជានាឱកាសនេះ នឹងរួមចំណែកពូនជ្រុំ និងលើកកម្ពស់ទំនាក់ទំនងដ៏ល្អរវាងប្រទេស និងប្រជាជន នៃប្រទេសទាំងពីរ ដែលមានស្រាប់ឱ្យកាន់តែរឹងមាំថែមទៀត ដើម្បីជាគុណប្រយោជន៍ដ៏ធំធេងទាំងពេលបច្ចុប្បន្ន និងពេលអនាគត។

ក្នុងនាមគណៈប្រតិភូ លោកជំទាវ **ង្វៀន ធីថាញ់** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្ដេចប្រធានព្រឹទ្ធសភា ដែលបានចំណាយពេលដ៏មានតម្លៃទទួលជួបគណៈប្រតិភូនាពេលនេះ។ លោកជំទាវបានជម្រាបថា នេះជាលើកទី១ហើយ ដែលលោកជំទាវបានមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ក្នុងនាមប្រធានសមាគមមិត្តភាពវៀតណាម-កម្ពុជា។ លោកជំទាវ បានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើនយ៉ាងឆាប់រហ័សលើគ្រប់វិស័យរបស់ប្រទេសកម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល។

លោកជំទាវ **ង្វៀន ធីថាញ់** បានវាយតម្លៃខ្ពស់ចំពោះប្រទេសកម្ពុជា ដែលឈានមុខគេក្នុងការគ្រប់គ្រងជំងឺកូវីដ-១៩ និងបានស្ដារ និងអភិវឌ្ឍសេដ្ឋកិច្ចឡើងវិញយ៉ាងឆាប់រហ័ស។ ជាមួយគ្នានោះ លោកជំទាវបានសម្ដែងនូវការអបអរសាទរចំពោះសមិទ្ធផលនានា ដែលប្រទេសកម្ពុជាសម្រេចបាន ក្រោមការដឹកនាំរបស់ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ដូចជាការទទួលបានជោគជ័យក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ និងការទទួល





*ទិដ្ឋភាពក្នុងពិធីជំនួបសម្ដែងការគួរសម*



*ទិដ្ឋភាពក្នុងពិធីជំនួបសម្ដែងការគួរសម*

ធ្វើជាប្រធានអាស៊ាន និងAIPA ព្រមទាំងធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំស៊ីហ្គេមនៅឆ្នាំ២០២៣ខាងមុខ។

លោកជំទាវ **ង្វៀន ធីថាញ់** បានបញ្ជាក់ថា ក្នុងរយៈពេល៥៥ឆ្នាំកន្លងទៅ ចាប់តាំងពីការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ រដ្ឋាភិបាល និងប្រជាជន នៃប្រទេសទាំងពីរ បានពូនជ្រំទំនាក់ទំនងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការបានយ៉ាងល្អប្រពៃ តាមទស្សនៈ “អ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ និងស្ថិតស្ថេរ” ហើយភាពជោគជ័យ និងការសប្បាយរីករាយរបស់កម្ពុជា គឺជាជោគជ័យ និងការសប្បាយរីករាយរបស់វៀតណាម។

ក្នុងនាមប្រជាជនវៀតណាម លោកជំទាវ **ង្វៀន ធីថាញ់** បានថ្លែងអំណរគុណចំពោះព្រះមហាក្សត្រ ព្រឹទ្ធសភា រដ្ឋ-សភា រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដែលតែងតែជួយគាំទ្រនិងពូនជ្រំទំនាក់ទំនងមិត្តភាពល្អជាប្រពៃណីរវាងប្រទេសទាំងពីរ។ ឆ្លៀតក្នុងឱកាសនោះ លោកជំទាវបានពាំនាំនូវការសួរសុខទុក្ខពីសំណាក់ឯកឧត្តមអគ្គលេខាបក្ស ឯកឧត្តមប្រធានរដ្ឋ ឯកឧត្តមនាយករដ្ឋមន្ត្រី និងឯកឧត្តមប្រធានរដ្ឋសភា ជូនចំពោះសម្ដេចប្រធានព្រឹទ្ធសភា។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ដំណើរទស្សន-កិច្ចរបស់គណៈប្រតិភូនាពេលនេះធ្វើឡើងស្របពេលដែលប្រទេសទាំងពីរបាននឹងកំពុងប្រារព្ធខួបអនុស្សាវរីយលើកទី៥៥ឆ្នាំ ថ្ងៃបង្កើតទំនាក់ទំនងការទូត និងជាឆ្នាំមិត្តភាពកម្ពុជា-វៀតណាម។ ប្រទេសទាំងពីរបានរៀបចំកម្មវិធីសកម្មភាពជាច្រើន ដូចជាការផ្លាស់ប្ដូរទស្សនកិច្ចទៅវិញទៅមករវាងថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ អាជ្ញាធរខេត្ត ក្រុង។ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ ប្រទេសទាំងពីរបានប្រារព្ធមីទ្ទិញដើម្បីអបអរសាទរខួបលើកទី៥៥ឆ្នាំ ប្រកបដោយបរិយាកាសសប្បាយរីករាយយ៉ាងក្រៃលែង។ ក្នុងរយៈពេល៥៥ឆ្នាំកន្លងទៅ ប្រទេសទាំងពីរធ្លាប់បានឆ្លងកាត់នូវវិញ្ញាសារដ៏លំបាកស្មុគស្មាញជាច្រើន ហើយបានរួមសាមគ្គីគ្នារឹងមាំ ប្រយុទ្ធប្រឆាំងសត្រូវរួម ដើម្បីបុព្វហេតុឯករាជ្យភាព អធិបតេយ្យភាព បូរណភាព និងការអភិវឌ្ឍ។ ហេតុនេះ ថ្នាក់ដឹកនាំបច្ចុប្បន្នត្រូវបន្តខិតខំរក្សាប្រពៃណីសាមគ្គីភាព មិត្តភាពឱ្យកាន់តែរឹងមាំថែមទៀត ដើម្បីទុកជាមរតកសម្រាប់ថ្នាក់ដឹកនាំជំនាន់ក្រោយៗនៃប្រទេសទាំងពីរ។

សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវសេចក្ដីពេញចិត្តជាខ្លាំងចំពោះចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហ-ប្រតិបត្តិការរវាងប្រទេស និងប្រជាជនទាំងពីរ ដែលបន្តរីកចម្រើនលើគ្រប់វិស័យ ពីមួយថ្ងៃទៅមួយថ្ងៃកាន់តែស៊ី-ជម្រៅមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងរឹងមាំយូរអង្វែង ក្រោមស្មារតី “ភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ស្ថិរភាពយូរអង្វែង”។

សភា រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ប្រកាន់ខ្ជាប់ខ្ជួនឥតងាករេ ដោយចាត់ទុកវៀតណាម គឺជាមិត្តល្អ ជាបងប្អូនល្អ ជាអ្នកជិតខាងល្អ និងជាដៃគូល្អ។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ព្រឹទ្ធសភាតែងតែគាំទ្រនិងលើកទឹកចិត្តដល់រដ្ឋាភិបាលនៃប្រទេសទាំងពីរ អនុវត្តន៍រាល់កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល នៃប្រទេសទាំងពីរ។ ជាមួយគ្នានោះ សម្ដេចបានវាយតម្លៃខ្ពស់ និងអបអរសាទរចំពោះសមិទ្ធផលទាំងឡាយដែលសមាគមមិត្តភាពនៃប្រទេសទាំងពីរសម្រេចបាន ជាពិសេសក្នុងការជួយឧបត្ថម្ភគាំទ្រគ្នាទៅវិញទៅមក ទាំងស្មារតី សម្ភារ និងថវិកា ក៏ដូចជាការឃោសនាអប់រំឱ្យប្រជាជន នៃប្រទេសទាំងពីរបានយល់ច្បាស់អំពី សភាពការណ៍ និងសមិទ្ធផលរួមនៃប្រទេសទាំងពីរ ក្នុងនោះឱ្យយល់ច្បាស់អំពីកត្តាស្លាប់រស់នៃចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។ ប្រជាជននៃប្រទេសទាំងពីរមានសេចក្ដីសប្បាយរីករាយណាស់ ដោយមើលឃើញរដ្ឋាភិបាលនៃប្រទេសទាំងពីរបានកសាងខ្សែបន្ទាត់ព្រំដែនឱ្យក្លាយជាខ្សែបន្ទាត់ព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងអភិវឌ្ឍន៍។

សម្ដេចប្រធានព្រឹទ្ធសភាបានលើកទឹកចិត្តឱ្យសមាគមមិត្តភាព នៃប្រទេសទាំងពីរ បន្តនូវការខិតខំប្រឹងប្រែងពូនជ្រំទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែរឹងមាំ និងខ្លាំងក្លាជាងនេះទៀត ដែលគ្មានអ្នកណាមកបំបែកបំបាក់បានឡើយ។

ក្នុងនាមព្រឹទ្ធសភា សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងការអបអរសាទរដ៏ស្មោះស្ម័គ្រចំពោះសមិទ្ធផលដ៏ធំធេង ដែលរដ្ឋាភិបាល និងប្រជាជនវៀតណាមសម្រេចបានក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់ខ្លួន។ សម្ដេចមានជំនឿថា ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់រដ្ឋាភិបាល និងសភាវៀតណាម វៀតណាមនឹងបន្តសម្រេចបាននូវសមិទ្ធផលសង្គម-សេដ្ឋកិច្ចធំៗបន្ថែមទៀត ក្នុងការអនុវត្តសេចក្ដីសម្រេចរបស់មហាសន្និបាតលើកទី១៣ នៃបក្សកុម្មុយនីស្តវៀតណាម។

សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំកំពូល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានផ្ដាំផ្ញើសួរសុខទុក្ខចំពោះសម្ដេច។ តាមរយៈគណៈប្រតិភូ សម្ដេចបានផ្ដាំផ្ញើសួរសុខទុក្ខដោយសេចក្ដីនឹករលឹកជូនចំពោះថ្នាក់ដឹកនាំជាន់ខ្ពស់ និងរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាមទាំងអស់។ សម្ដេចបានប្រសិទ្ធពរគណៈប្រតិភូ សូមមានសុខភាពល្អ និងដំណើរទស្សនកិច្ចនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាបានប្រកបដោយជោគជ័យ៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្ដេចប្រធានព្រឹទ្ធសភាថតរូបអនុស្សាវរីយជាមួយគណៈប្រតិភូវៀតណាម*

# សម្ដេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ចូលជួបសម្ដែងការគួរសម



*លោក Kim Jung Nam និងសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ*

នារសៀលថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ នៅវិមានព្រឹទ្ធសភា វេលាម៉ោង១៤:៣០នាទី សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យលោក Kim Jung Nam ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល (Global Life Sharing) នៃសាធារណរដ្ឋកូរ៉េចូលជួបសម្ដែងការគួរសម ក្នុងឱកាសដែលលោកប្រធានមូលនិធិដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។

សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវការស្វាគមន៍ចំពោះលោកប្រធានមូលនិធិ និងគណៈប្រតិភូ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។ ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនាឱកាសនោះ បានឆ្លុះបញ្ចាំងអំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលជាមួយនឹងប្រជាជនកម្ពុជា និងជាមូលដ្ឋានដល់ការរួមចំណែកពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរ ដើម្បីគុណប្រយោជន៍សម្រាប់ប្រជាជននៃប្រទេសទាំងពីរ ទាំងពេលបច្ចុប្បន្ន និងពេលអនាគត។

ក្នុងនាមគណៈប្រតិភូ លោក Kim Jung Nam បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្ដេចប្រធានព្រឹទ្ធសភាដែលបានចំណាយពេលដ៏មានតម្លៃទទួលជួបគណៈប្រតិភូនាពេលនោះ។ ក្នុងអំឡុងពេលដែលគណៈប្រតិភូស្នាក់នៅប្រទេសកម្ពុជា បានមើលឃើញអំពីការអភិវឌ្ឍរីកចម្រើនរបស់ប្រទេសកម្ពុជាយ៉ាងឆាប់រហ័ស។ នៅពេលត្រឡប់ទៅមាតុប្រទេសវិញ គណៈប្រតិភូនឹងខិតខំធ្វើយ៉ាងណារៀបចំផ្ដល់ជំនួយឱ្យប្រទេសកម្ពុជាបានកាន់តែច្រើនឡើងថែមទៀត។

លោក Kim Jung Nam បានបញ្ជាក់ថា ការចុះអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចព្រមព្រៀងផ្ដល់មនុស្សធម៌ដល់ព្រឹទ្ធសភាកម្ពុជារយៈពេល៤ឆ្នាំនេះ នឹងរួមចំណែកដល់ការអភិវឌ្ឍប្រទេសកម្ពុជា។

សម្ដេចប្រធានព្រឹទ្ធសភាបានវាយតម្លៃខ្ពស់ចំពោះ





*ទិដ្ឋភាពក្នុងពិធីជំនួបសម្ដែងការគួរសម*

តួនាទីរបស់មូលនិធិចែករំលែកសង្គ្រោះអាយុជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ចំពោះសកម្មភាពការងារមនុស្សធម៌ក្នុងពិភពលោក ដែលបានចូលរួមចំណែកដោះស្រាយបញ្ហាខ្វះខាតក្នុងវិស័យសុខាភិបាល ប្រព័ន្ធវេជ្ជសាស្ត្រ និងការអប់រំផ្នែកវេជ្ជសាស្ត្រដល់បណ្តាប្រទេសកំពុងអភិវឌ្ឍក្នុងពិភពលោក។

សម្តេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមូលនិធិចែករំលែកសង្គ្រោះអាយុជីវិតសកល ដែលបានផ្តល់ជំនួយមនុស្សធម៌ដល់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជានូវសម្ភារវេជ្ជសាស្ត្រលើកទី១ចំនួន២៣មុខ សម្រាប់សង្គ្រោះជីវិតប្រជាជនកម្ពុជាដែលកំពុងជួបការលំបាក និងឧបករណ៍វេជ្ជសាស្ត្រសំខាន់ៗមួយចំនួនទៀតដល់មន្ទីរពេទ្យផងដែរ។ កាយវិការដ៏សប្បុរសរបស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល ពិតជាបានរួមចំណែកជួយលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា និងផ្តល់កាលានុវត្តភាពឱ្យកម្ពុជាបើកដំណើរការពេញលេញនូវសង្គម-សេដ្ឋកិច្ចឡើងវិញតាមគន្លងប្រក្រតីភាពថ្មី។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវសេចក្តីរីករាយចំពោះគម្រោងជំនួយរបស់មូលនិធិចែករំលែកសង្គ្រោះអាយុជីវិតសកលសម្រាប់ការសាងសង់មជ្ឈមណ្ឌលស្តារកាយសម្បទាសម្តេចតេជោ ដែលជាតម្រូវការចាំបាច់ និងជាក់ស្តែងរបស់ប្រជាជនកម្ពុជា។ សម្តេចបានស្នើឱ្យការពិភាក្សានេះឈានទៅដល់ការអនុវត្តគម្រោងឱ្យបានជោគជ័យឆាប់ៗនាពេលខាងមុខ។

សម្តេចប្រធានព្រឹទ្ធសភាបានវាយតម្លៃខ្ពស់អំពីចំណងមិត្តភាព សាមគ្គីភាព រវាងប្រទេស សភា និងប្រជាជន នៃប្រទេសទាំងពីរ ដែលមានការរីកចម្រើនឥតឈប់ឈរ តាមរយៈការផ្លាស់ប្តូរទស្សនកិច្ច បទពិសោធន៍ វប្បធម៌ ប្រពៃណី និងលើវិស័យជាច្រើនទៀត។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវការអបអរសាទរដល់ការចុះអនុស្សរណៈយោគយល់គ្នារវាងព្រឹទ្ធសភាកម្ពុជា និងមូលនិធិចែករំលែកសង្គ្រោះអាយុជីវិតសកល នៃសាធារណរដ្ឋកូរ៉េនាថ្ងៃនោះ ដែលតាមរយៈអនុស្សរណៈយោគយល់គ្នានោះ មូលនិធិចែករំលែកសង្គ្រោះអាយុជីវិតសកល និងបន្តកិច្ចសហប្រតិបត្តិការវិស័យសុខាភិបាល និងការងារសប្បុរសធម៌ជាមួយនឹងព្រឹទ្ធសភាកម្ពុជាក្នុងរយៈពេល៤ឆ្នាំ ដែលគិតជាទឹកប្រាក់ចំនួន១០លានដុល្លារអាមេរិក។

សម្តេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរជូនគណៈប្រតិភូមានសុខភាពល្អបរិបូរណ៍ និងទទួលបានជោគជ័យគ្រប់ភារកិច្ច ក្នុងឱកាសស្នាក់នៅប្រទេសកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គឹម សិទ្ធី)



*សម្តេចប្រធានព្រឹទ្ធសភាថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូមូលនិធិចែករំលែកសង្គ្រោះជីវិតសកល*

# សម្ដេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យឯកឧត្តមឯកអគ្គរដ្ឋទូត សាធារណរដ្ឋអាមេនី ចូលជួបសម្ដែងការគួរសម



*ឯកឧត្តម Vahram Kazhoyan និងសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ*

នាព្រឹកថ្ងៃសុក្រ ទី១៩ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ៩:០០នាទី សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម Vahram Kazhoyan ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋអាមេនី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្ដែងការគួរសម នៅវិមានព្រឹទ្ធសភា។

ក្នុងនាមព្រឹទ្ធសភា និងក្នុងនាមសម្ដេចផ្ទាល់ សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងការស្វាគមន៍ និងអបអរសាទរចំពោះឯកឧត្តម Vahram Kazhoyan ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋអាមេនី ប្រចាំព្រះរាជាណាចក្រកម្ពុជា។

ក្នុងឱកាសនោះ ឯកឧត្តម Vahram Kazhoyan បានជម្រាបជូនសម្ដេចប្រធានព្រឹទ្ធសភាជ្រាបថា ឯកឧត្តមគឺជាឯកអគ្គរដ្ឋទូតទី១របស់សាធារណរដ្ឋអាមេនី ប្រចាំព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមបានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។ តាមរយៈបេសកកម្មការទូតរបស់ឯកឧត្តមនៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមនឹងខិតខំប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយចិត្តក្នុងការពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។

ឯកឧត្តមឯកអគ្គរដ្ឋទូតបានរំលឹកអំពី កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរលើឆាកអន្តរជាតិជាច្រើន ដូចជា៖ ក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ អង្គការយូនីស្កូ និងការខិតខំរួមគ្នាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍។ ជាមួយគ្នានោះ នៅទសវត្សរ៍ទី៥០ ទី៦០ ប្រទេសអាមេនីធ្លាប់បានទទួលនិស្សិតកម្ពុជាជាច្រើនមកសិក្សានៅប្រទេសអាមេនី។

ឯកឧត្តមឯកអគ្គរដ្ឋទូតបានជម្រាបជូនសម្ដេចប្រធានព្រឹទ្ធសភាជ្រាប អំពីជំនួបពិភាក្សារវាងឯកឧត្តម និងឯកឧត្តមរដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយភាគីទាំងពីរបានយល់ស្របគ្នាក្នុងការពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរលើវិស័យមួយចំនួន ព្រមទាំងបានត្រៀមចុះហត្ថលេខាលើឯកសារគតិយុត្តជាច្រើន ដើម្បីជំរុញលើកកម្ពស់កិច្ចសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្ម វិនិយោគ និងវិស័យទេសចរណ៍។

សម្ដេចប្រធានព្រឹទ្ធសភាមានជំនឿជឿជាក់ថា ក្នុងអាណត្តិបេសកកម្មការទូតរបស់ឯកឧត្តម ឯកឧត្តមនឹងខិតខំលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើន ដើម្បីជាគុណប្រយោជន៍សម្រាប់ប្រជាជន និងប្រទេសទាំងពីរ ទាំងពេលបច្ចុប្បន្ន



*ទិដ្ឋភាពក្នុងពិធីជំនួបសម្ដែងការគួរសម*

និងក្នុងពេលអនាគត។

សម្ដេចប្រធានព្រឹទ្ធសភាបានរំលឹកថា ក្រសួងការបរទេសនៃប្រទេសទាំងពីរបានចុះអនុស្សរណៈយោគយល់ស្ដីពីកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគី កាលពីឆ្នាំ២០១៨ និងបានរៀបចំកិច្ចពិគ្រោះយោបល់ទ្វេភាគីលើកទី១ ក្នុងឆ្នាំ២០១៩។ សម្ដេចបានកត់សម្គាល់ឃើញថា ទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ និងវិស័យមួយចំនួនមិនទាន់មានទំនាក់ទំនងគ្នាដោយទូលំទូលាយ។ សម្ដេចបានលើកទឹកចិត្តឱ្យរដ្ឋាភិបាលទាំងពីរ បន្តពិគ្រោះយោបល់តាមយន្តការដែលមានស្រាប់ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ឱ្យមានលទ្ធផលជាក់ស្ដែង មានផលប្រយោជន៍ទៅវិញទៅមក និងបន្តគាំទ្រគ្នាលើកិច្ចសហប្រតិបត្តិការពហុភាគីឱ្យបានកាន់តែទូលំទូលាយ ដើម្បីរួមចំណែកដល់ការនាំមកនូវសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍតំបន់ និងសកលលោក។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា មុនវិបត្តិកូវីដ-១៩ សេដ្ឋកិច្ចកម្ពុជាមានអត្រាកំណើនប្រចាំឆ្នាំជាមធ្យម ក្នុងរង្វង់ ៧%។ ប៉ុន្តែនៅឆ្នាំ២០២០ ក្នុងបរិបទកូវីដ-១៩ សេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះមក -៣,១%។ ដោយសារតែរាជរដ្ឋាភិបាលកម្ពុជាគ្រប់គ្រងជំងឺកូវីដ-១៩បានយ៉ាងល្អ កម្ពុជាបានបើកដំណើរការពេញលេញនូវសកម្មភាពសង្គម-សេដ្ឋកិច្ចតាមគន្លងប្រក្រតីភាពថ្មី។ កម្ពុជាទទួលបានចំណាត់ថ្នាក់ខ្ពស់ក្នុងពិភពលោក ជាប្រទេសងើបចេញពីជំងឺកូវីដ-១៩ យ៉ាងលឿន និងស្ដារសេដ្ឋកិច្ចឡើងវិញយ៉ាងឆាប់រហ័ស។ តាមការព្យាករណ៍សេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងទុកថា មានកំណើនក្នុងអត្រា ៥,៤% ក្នុងឆ្នាំ២០២២ និង៦,៦% ក្នុងឆ្នាំ២០២៣។ ដោយអនុវត្តទទួលបានជោគជ័យនូវយុទ្ធសាស្ត្រវ៉ាក់សាំង បច្ចុប្បន្នកម្ពុជាជាគោលដៅទេសចរណ៍សុវត្ថិភាព ហេតុនេះសម្ដេចបានអំពាវនាវសូមឱ្យជួយផ្សព្វផ្សាយ និងជំរុញអ្នកទេសចរអាមេនីមកកម្សាន្ត និងទស្សនាកម្ពុជាឱ្យបានកាន់តែច្រើន។

ទោះបីជំងឺកូវីដ-១៩ បានថយចុះដូចពេលបច្ចុប្បន្នក៏ដោយ នៅទូទាំងពិភពលោកកំពុងទទួលរងនូវបញ្ហាប្រឈមថ្មីៗថែមទៀត ដែលជះឥទ្ធិពលដល់ការកើនឡើងនៃអតិផរណានៅគ្រប់ទីកន្លែង និងកំពុងតែដាក់សម្ពាធដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន។ ព្រឹទ្ធសភាកម្ពុជាមើលឃើញថា ក្នុងស្ថានភាពដ៏លំបាកដែលពិបាកប៉ាន់ស្មាននេះ ប្រទេសទាំងអស់ត្រូវតែមានកិច្ចសហប្រតិបត្តិការជាមួយគ្នាយ៉ាងរឹងមាំ ហើយត្រូវជួយគ្នាទៅវិញទៅមកជាងពេលណាៗទាំងអស់។ ជាមួយគ្នានេះ តាមរយៈការអនុវត្តមុខងារស្នូលទាំងបី ជាអាទិ៍៖ មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ព្រឹទ្ធសភាកម្ពុជាបានរួមចំណែកយ៉ាងសកម្មដើម្បីថែរក្សាសន្តិភាព សន្តិសុខសង្គម ក៏ដូចជាការការពារឯករាជ្យភាព អធិបតេយ្យភាព បូរណភាព និងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនជាបន្តបន្ទាប់។ ចំពោះទំនាក់ទំនងអន្តរជាតិ សភាកម្ពុជា គឺជាសមាជិករបស់អង្គការសភាតំបន់ និងពិភពលោកផងដែរ។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០២២ ប្រទេសកម្ពុជានឹងខិតខំប្រឹងប្រែង ដើម្បីពង្រឹង និងពង្រីកនូវកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់អាស៊ាន និងជាមួយដៃគូអាស៊ានផ្សេងទៀត។

ក្នុងនាមព្រឹទ្ធសភា និងក្នុងនាមសម្ដេចផ្ទាល់ សម្ដេចប្រធានព្រឹទ្ធសភាត្រៀមខ្លួនជានិច្ច ដើម្បីធ្វើកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយឯកឧត្ដមឯកអគ្គរដ្ឋទូត និងស្ថានទូតអាមេនី ដើម្បីរួមចំណែកបន្តពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការសម្រាប់នូវផលប្រយោជន៍ទៅវិញ-ទៅមករបស់ប្រជាជន និងប្រទេសទាំងពីរឱ្យកាន់តែមានការរីកចម្រើនថែមទៀត។

សម្ដចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរជូនឯកឧត្តមឯកអគ្គរដ្ឋទូតបំពេញបេសកកម្មការទូតនៅព្រះជាណាចក្រ-កម្ពុជា ទទួលបានសុខភាពល្អបរិបូរណ៍ និងទទួលបានជោគជ័យ៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*ឯកឧត្តម Vahram Kazhoyan ថតរូបអនុស្សាវរីយ៍ជាមួយសម្ដេចប្រធានព្រឹទ្ធសភា*

# សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ទទួលជួបប្រធានគណៈទាក់ទងបរទេស នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្ដវៀតណាម



*ឯកឧត្ដម ឡេ ហាយជុង និងសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ*

នារសៀលថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ១៤:៣០នាទី នៅវិមានព្រឹទ្ធសភា សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបឯកឧត្ដម **ឡេ ហាយជុង** សមាជិកគណៈ-កម្មាធិការមជ្ឈិមបក្ស និងជាប្រធានគណៈទាក់ទងបរទេស នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្ដវៀតណាម ក្នុងឱកាសដែលឯកឧត្ដមដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមព្រឹទ្ធសភា និងក្នុងនាមសម្ដេចផ្ទាល់ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** បានសម្ដែងនូវសេចក្ដីរីករាយ និងសូមស្វាគមន៍យ៉ាងកក់ក្ដៅចំពោះគណៈប្រតិភូ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចជាមិត្តភាព និងផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។ សម្ដេចជឿជាក់ថា ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៅកម្ពុជានាឱកាសនេះ បាននាំមកនូវការពង្រឹងពង្រីកចំណងសាមគ្គីភាព មិត្តភាពជាប្រពៃ ភាពជាអ្នកជិតខាងល្អ និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងប្រជាជននៃប្រទេសទាំងពីរឱ្យកាន់តែរឹងមាំថែមទៀត ដើម្បីជាគុណប្រយោជន៍ដ៏ធំធេង ទាំងពេលបច្ចុប្បន្ន និងទៅអនាគត។

ក្នុងឱកាសនោះឯកឧត្ដម **ឡេ ហាយជុង** បានជម្រាបជូនសម្ដេចប្រមុខរដ្ឋស្ដីទីជ្រាបថា នេះគឺជាលើកទី១ហើយដែលឯកឧត្ដមបានមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ក្នុងនាមជាប្រធានគណៈទាក់ទងបរទេស នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្ដវៀតណាម។ ដំណើរទស្សនកិច្ចនេះស្របពេលប្រទេសទាំងពីរប្រារព្ធខួបអនុស្សាវរីយលើកទី៥៥ នៃការបង្កើតទំនាក់ទំនងការទូតកម្ពុជា-វៀតណាម។

ឯកឧត្ដម **ឡេ ហាយជុង** បានសម្ដែងនូវសេចក្ដីរីករាយ ដោយមើលឃើញទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកាន់តែល្អប្រសើរ។ ជាមួយគ្នានោះ ឯកឧត្ដម





*ទិដ្ឋភាពក្នុងពិធីជំនួបសម្ដែងការគួរសម*



*ទិដ្ឋភាពក្នុងពិធីជំនួបសម្ដែងការគួរសម*

បានសម្ដែងនូវការអបអរសាទរចំពោះសមិទ្ធផលនានា ដែលប្រទេសកម្ពុជាសម្រេចបាន ក្រោមការដឹកនាំរបស់ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ជាពិសេសបានវាយតម្លៃខ្ពស់ចំពោះប្រទេសកម្ពុជាដែលឈានមុខគេក្នុងការគ្រប់គ្រងជំងឺកូវីដ-១៩ និងបានស្ដារ និងអភិវឌ្ឍន៍សេដ្ឋកិច្ចឡើងវិញយ៉ាងឆាប់រហ័ស។

ឯកឧត្តម **ឡៃ ហាយជុង** បានបញ្ជាក់ថា ប្រទេសវៀតណាមចាត់ទុកប្រទេសកម្ពុជា ជាបងប្អូនល្អ ជាអ្នកជិតខាងល្អ និងបានប្រកៀកស្មាគ្នាក្នុងការប្រយុទ្ធប្រឆាំងសត្រូវ ដើម្បីបុព្វហេតុឯករាជ្យភាព អធិបតេយ្យភាព បូរណភាព និងការអភិវឌ្ឍរបស់ប្រទេសនីមួយៗ។

ឯកឧត្តម **ឡៃ ហាយជុង** សង្កេតឃើញថា រដ្ឋសភាវៀតណាម និងព្រឹទ្ធសភាកម្ពុជា មានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រពៃ។ ជាមួយគ្នានោះ ឯកឧត្តមបានស្នើសុំឱ្យជំរុញសកម្មភាព និងការអនុវត្តកិច្ចព្រមព្រៀងនៃប្រទេសទាំងពីរ ដើម្បីពង្រឹកពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិ និងសន្តិសុខ ក៏ដូចជាការសហការគ្នាដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងការងារបោះបង្គោលព្រំដែន ដើម្បីទទួលបានលទ្ធផលល្អថែមទៀត។

សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** បានបញ្ជាក់ថា ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនាពេលនេះធ្វើឡើងស្របពេលដែលប្រទេសទាំងពីរប្រារព្ធខួបអនុស្សាវរីយលើកទី៥៥ឆ្នាំ ថ្ងៃបង្កើតទំនាក់ទំនងការទូត និងជាឆ្នាំមិត្តភាពកម្ពុជា-វៀតណាម។ ប្រទេសទាំងពីរបានរៀបចំកម្មវិធីសកម្មភាពជាច្រើន ដូចជាថ្នាក់ដឹកនាំជាន់ខ្ពស់ ថ្នាក់ដឹកនាំកំពូលបានផ្ញើសារជូនគ្នាទៅវិញទៅមក ផ្លាស់ប្ដូរទស្សនកិច្ចទៅវិញទៅមករវាងថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ អាជ្ញាធរខេត្តក្រុង។ ក្នុងរយៈពេល៥៥ឆ្នាំកន្លងទៅ ប្រជាជន នៃប្រទេសទាំងពីរធ្លាប់បានឆ្លងកាត់នូវវិញ្ញាសារដ៏លំបាកស្មុគស្មាញជាច្រើន ហើយបានរួមសាមគ្គីគ្នារឹងមាំប្រយុទ្ធប្រឆាំងសត្រូវរួម ដើម្បីបុព្វហេតុឯករាជ្យភាព អធិបតេយ្យភាព បូរណភាព និងការរីកចម្រើនរបស់ប្រទេសនីមួយៗ។ ថ្នាក់ដឹកនាំបច្ចុប្បន្នត្រូវបន្តខិតខំរក្សាប្រពៃណីសាមគ្គីភាព មិត្តភាពរវាងប្រទេសទាំងពីរឱ្យកាន់តែរឹងមាំថែមទៀត ដើម្បីទុកជាមរតកសម្រាប់ជំនាន់ក្រោយនៃប្រទេសទាំងពីរ។

សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** បានសម្ដែងនូវសេចក្ដីពេញចិត្តចំពោះទំនាក់ទំនងចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេស និងប្រជាជនទាំងពីរ លើពាក្យស្លោក “ភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ស្ថិរភាពយូរអង្វែង”។ ទំនាក់ទំនងដ៏ល្អនេះមិនគ្រាន់តែនាំមកនូវការអភិវឌ្ឍប្រទេសទាំងពីរប៉ុណ្ណោះទេ នឹងទាំងបានរួមចំណែក

ដល់ការថែរក្សាសន្តិភាព ស្ថិរភាពក្នុងតំបន់ និងសកលលោកផងដែរ។

ក្នុងនាមប្រជាជនកម្ពុជា សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសម្តែងនូវការដឹងគុណចំពោះកងទ័ព ប្រជាជន និងបក្សកុម្មុយនីស្តវៀតណាម ដែលតែងតែជួយគាំទ្រដល់បុព្វហេតុដ៏ត្រឹមត្រូវ យុត្តិធម៌របស់ប្រជាជនកម្ពុជាក្នុងគ្រប់ដំណាក់កាលទាំងអស់។ សភា រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាប្រកាន់ខ្ជាប់ខ្ជួនឥតងាករេ ដោយចាត់ទុកវៀតណាមគឺជាមិត្តល្អ ជាបងប្អូនល្អ ជាអ្នកជិតខាងល្អ និងជាដៃគូល្អ។ ប្រទេសកម្ពុជាគឺប្រទេសដែលគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩ បានយ៉ាងល្អប្រសើរ ហើយបានកំពុងក្លាយជាគោលដៅទេសចរណ៍សុវត្ថិភាព ដែលធ្វើឱ្យចំនួនអ្នកទេសចរកើនឡើងជាបន្តបន្ទាប់។

សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានគាំទ្រយ៉ាងពេញទំហឹង និងលើកទឹកចិត្តដល់រដ្ឋាភិបាលនៃប្រទេសទាំងពីរ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលនូវរាល់កិច្ចព្រមព្រៀង និងអនុស្សរណៈយោគយល់គ្នាដែលបានចុះហត្ថលេខារួចហើយ ក្នុងន័យដើម្បីឱ្យរដ្ឋាភិបាលនៃប្រទេសទាំងពីរខិតខំប្រឹងប្រែងឱ្យសម្រេចនូវចក្ខុវិស័យដែលរដ្ឋាភិបាលនៃប្រទេសទាំងពីរបានសម្រេចរួមគ្នា។

ក្នុងនាមប្រជាជនកម្ពុជា សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសម្តែងការអបអរសាទរដ៏ស្មោះស្ម័គ្រចំពោះសមិទ្ធផលដ៏ធំធេងដែលរដ្ឋាភិបាល និងប្រជាជនវៀតណាមសម្រេចបាន ក្រោមការដឹកនាំដ៏ត្រឹមត្រូវនិងភ្លឺស្វាងរបស់បក្សកុម្មុយនីស្តវៀតណាម។ សម្តេចមានជំនឿថា ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់បក្សកុម្មុយនីស្តវៀតណាម ប្រជាជនវៀតណាមនឹងបន្តសម្រេចបាននូវសមិទ្ធផលសង្គម-សេដ្ឋកិច្ចជាច្រើនបន្ថែមទៀត ក្នុងការអនុវត្តសេចក្តីសម្រេចរបស់មហាសន្និបាតលើកទី១៣ នៃបក្សកុម្មុយនីស្តវៀតណាម។

សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានបញ្ជាក់ថា ព្រឹទ្ធសភាកម្ពុជាមានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយនឹងរដ្ឋសភាវៀតណាម ទាំងក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការទ្វេភាគី និងនៅលើឆាកអន្តរជាតិ ដូចជា៖ នៅក្របខ័ណ្ឌ IPU, AIPA, APF, APPF និង CLV ជាដើម។

តាមរយៈគណៈប្រតិភូ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានផ្តាំផ្ញើសួរសុខទុក្ខដោយសេចក្តីនឹករលឹក និងសេចក្តីគោរព ជូនឯកឧត្តមប្រធានរដ្ឋសភាវៀតណាម និងថ្នាក់ដឹកនាំជាន់ខ្ពស់ នៃសាធារណរដ្ឋសង្គមនិយមវៀតណាមទាំងអស់។ សម្តេចបានប្រសិទ្ធពរគណៈប្រតិភូ សូមមានសុខភាពល្អ និងដំណើរទស្សនកិច្ចនៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជាបានប្រកបដោយជោគជ័យ៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្តេចប្រធានព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូគណៈទាក់ទងបរទេសនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម*

# ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញជាអធិបតីភាពក្នុងពិធីចុះអនុស្សរណៈ នៃការយោគយល់គ្នាស្ដីពី កិច្ចព្រមព្រៀងផ្ដល់ជំនួយមនុស្សធម៌ដល់ព្រឹទ្ធសភា



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អញ្ជើញជាអធិបតីភាពក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា*

នារសៀលថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងគណៈកម្មការទី១០ព្រឹទ្ធសភា ជាមួយនឹងមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ស្ដីពីកិច្ចព្រមព្រៀងផ្ដល់ជំនួយមនុស្សធម៌ដល់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។

ក្នុងឱកាសនោះ លោក Kim Jung Nam ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ បានបញ្ជាក់ថា បន្ទាប់ពីទទួលលិខិតផ្លូវការពីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាកាលពីខែវិច្ឆិកា ឆ្នាំ២០២១ មូលនិធិចែករំលែកសង្គ្រោះជីវិតសកល បានរៀបចំដឹកជញ្ជូនជំនួយមកប្រទេសកម្ពុជាលើកទី១ នៅខែមេសា និងលើកទី២ ក្នុងឆ្នាំ២០២២។

លោក Kim Jung Nam បានជម្រាបជូនអង្គពិធីជ្រាបថា អនុស្សរណៈយោគយល់គ្នារវាងមូលនិធិចែករំលែកសង្គ្រោះអាយុជីវិតសកលនៃសាធារណរដ្ឋកូរ៉េ និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នឹងផ្ដល់ជំនួយមនុស្សធម៌ផ្នែកបរិក្ខារពេទ្យ និងសម្ភារផ្សេងៗ ក្នុងទំហំទឹកប្រាក់១០លានដុល្លារអាមេរិកក្នុងរយៈពេល៤ឆ្នាំ។ ការផ្ដល់ជំនួយរបស់មូលនិធិចែករំលែកសង្គ្រោះអាយុជីវិតសកល នឹងផ្ដល់ផលប្រយោជន៍ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។

ក្នុងនាមព្រឹទ្ធសភា ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានត្រៀមខ្លួនរួចជាស្រេចក្នុងការធ្វើកិច្ចសហការជាមួយនឹងមូលនិធិចែករំលែកសង្គ្រោះ



*ឯកឧត្តម Kim Jung Nam ឡើងថ្លែងសុន្ទរកថា*



*ឯកឧត្តម ម៉ម ប៊ុននាង ឡើងថ្លែងសុន្ទរកថា*



*ទិដ្ឋភាពក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងគណៈកម្មការទី១០ព្រឹទ្ធសភា និងមូលនិធិចែករំលែកសង្គ្រោះជីវិតសកល*

ជីវិតសកល ក្នុងការនាំយកជំនួយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល ចែកជូនដល់ដៃស្ថាប័នរដ្ឋ និងប្រជាពលរដ្ឋដែលត្រូវការពិតប្រាកដ ប្រកបដោយគណនេយ្យភាព តម្លាភាព និងមានប្រសិទ្ធភាព។

ឯកឧត្តម **ម៉ម ប៊ុននាង** បានបញ្ជាក់ថា តាមរយៈអនុស្សរណៈនេះ មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ នឹងផ្ដល់ជំនួយមនុស្សធម៌ដល់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាសម្ភារវេជ្ជសាស្ត្រ រួមមាន៖ ឱសថ ឧបករណ៍វេជ្ជសាស្ត្រ បរិក្ខារពេទ្យ និងសម្ភារប្រើប្រាស់ប្រចាំថ្ងៃ ដែលគិតជាថវិកាមានចំនួន១០.០០០.០០០$ (ដប់លានដុល្លារអាមេរិក) សម្រាប់រយៈពេល៤ឆ្នាំ គឺចាប់ពីខែសីហា ឆ្នាំ២០២២ ដល់ខែធ្នូ ឆ្នាំ២០២៥។ ជំនួយមនុស្សធម៌នេះ គឺពិតជាមានសារៈសំខាន់ ហើយបានឆ្លើយតបនឹងសេចក្ដីត្រូវការចាំបាច់របស់ប្រជាពលរដ្ឋទាំងនៅទីក្រុង និងនៅទីជនបទ។

ឯកឧត្តម **ម៉ម ប៊ុននាង** ជឿជាក់ថា បន្ទាប់ពីអនុស្សរណៈនេះបានចូលជាធរមានហើយ មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នឹងពិនិត្យបន្តអនុស្សរណៈផ្សេងទៀត ដើម្បីផ្ដល់ជំនួយមនុស្សធម៌បន្ថែមទៀត ក្នុងន័យធ្វើឱ្យគុណភាពជីវិតរបស់ប្រជាពលរដ្ឋកម្ពុជាកាន់តែប្រសើរឡើង៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ គង់ យ៉ារីន)



*ឯកឧត្តម ម៉ម ប៊ុននាង និងឯកឧត្តម Kim Jung Nam*



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ព្រមទាំងសមាជិក សមាជិកាព្រឹទ្ធសភា ថតរូបអនុស្សាវរីយជាមួយមូលនិធិចែករំលែកសង្គ្រោះជីវិតសកល*

## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាររសៀលថ្ងៃព្រហស្បតិ៍ ទី១១ ខែសីហា ឆ្នាំ ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមក្នុងពិធីបុណ្យគម្រប់ខួប១០០ថ្ងៃ ឧទ្ទិសកុសលជូនចំពោះដួងវិញ្ញាណក្ខន្ធសម្ដេចឧត្ដមទេពញាណ **ហ៊ុន ណេង** អតីតសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងជាអ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម នៅក្រុងកំពង់ចាម ខេត្តកំពង់ចាម។



❈នាព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសពឧបាសិកាកុសលចិត្ដាមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ពេន យុត** ត្រូវជាម្ដាយក្មេករបស់ឯកឧត្ដម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន នៅភូមិគ្រឹះលេខ៣៨ ផ្លូវ២៨៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមពិធីបុណ្យគម្រប់ខួប៧ថ្ងៃ ដើម្បីឧទ្ទិសកុសលដល់ដួងវិញ្ញាណក្ខន្ធមហាឧបាសិកា **ពេន យុត** កុសលចិត្ដាមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ ត្រូវជាម្ដាយក្មេករបស់ឯកឧត្ដម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញគោរពព្រះវិញ្ញាណក្ខន្ធព្រះអដ្ឋិសម្តេចព្រះបរមរាមា **នរោត្តម យុវនាថ** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តបទុមវត្តី រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញដង្ហែព្រះរាជដំណើរព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ស្តេចយាងទៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។



❈នារសៀលថ្ងៃពុធ ទី២៤ ខែសីហា ឆ្នាំ២០២២ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពមហាវីរិយាភិវឌ្ឍសិរី អគ្គមហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ **ខេវ៉ូ ស៊ុនស្រេង** ត្រូវជាឪពុកបង្កើតឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន នៅគេហដ្ឋានលេខ១៧ ផ្លូវលេខ៦០៤ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។



# គណៈកម្មការទី២ព្រឹទ្ធសភាចុះឈ្វេងយល់អំពីការពង្រឹងកិច្ចការរដ្ឋបាលឃុំ សង្កាត់ ក្រោយការបោះឆ្នោត នៅខេត្តព្រៃវែង




*គណៈកម្មការទី២ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយអាជ្ញាធរក្រុងព្រៃវែង*

នាថ្ងៃទី២៧ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ គណៈប្រតិភូគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា (គណៈកម្មការទី២) ដឹកនាំដោយឯកឧត្តម **ជា ចេដ្ឋ** ប្រធានគណៈកម្មការ បានអញ្ជើញចុះឈ្វេងយល់អំពីការពង្រឹងកិច្ចការរដ្ឋបាលឃុំ សង្កាត់ ក្រោយការបោះឆ្នោត សំដៅអភិវឌ្ឍមូលដ្ឋាន ធានាបានសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ នៅខេត្តព្រៃវែង។

គោលបំណងនៃដំណើរបេសកកម្មរយៈពេល២ថ្ងៃនេះ ដើម្បីឈ្វេងយល់កាន់តែស៊ីជម្រៅបន្ថែមទៀតលើបញ្ហាមួយចំនួនដូចជា៖ ការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយផ្តោតទៅលើការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពី ការគ្រប់គ្រង រដ្ឋបាលឃុំ សង្កាត់។ ការអនុវត្តថវិកាថ្នាក់ក្រោមជាតិ (ទទួល-ទូទាត់) និងបញ្ហាប្រឈម។ ប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាល ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។ សមត្ថភាពក្នុងការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ រយៈពេល៥ឆ្នាំ របស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ការបន្តអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅមូលដ្ឋាន។

ក្នុងឱកាសនោះ គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញជួបសវនាការការងារជាមួយនឹងសមាជិកក្រុមប្រឹក្សាក្រុង សង្កាត់ ស្មៀន អធិការនគរបាលក្រុង និងនគរបាលប៉ុស្តិ៍រដ្ឋបាល ក្រុងព្រៃវែង ដើម្បីសិក្សាឈ្វេងយល់អំពីការពង្រឹងកិច្ចការរដ្ឋបាលឃុំ សង្កាត់ ក្រោយការបោះ-





*ទិដ្ឋភាពអ្នកចូលរួមក្នុងពិធីជំនួបពិភាក្សាការងារ*





*គណៈកម្មការទី២ព្រឹទ្ធសភាជួបពិភាក្សាជាមួយអាជ្ញាធរខេត្តព្រៃវែង*

ឆ្ពោតសំដៅអភិវឌ្ឍមូលដ្ឋាន ធានាបានសុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ នៅសាលាក្រុងព្រៃវែង និងអញ្ជើញជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធរខេត្តព្រៃវែង ដឹកនាំដោយឯកឧត្តម **សួន សុម៉ាលីន** អភិបាលរង នៃគណៈអភិបាលខេត្តព្រៃវែង ដោយមានការអញ្ជើញចូលរួមពីមន្ទីរពាក់ព័ន្ធនៅសាលាខេត្តព្រៃវែង។

មានប្រសាសន៍ក្នុងឱកាសជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ និងអាជ្ញាធរខេត្តព្រៃវែង ឯកឧត្តម **ខាវ ខេង្គ** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះរដ្ឋបាលខេត្ត និងមន្ត្រីរាជការជុំវិញខេត្ត ដែលបានខិតខំបំពេញការងារ អភិវឌ្ឍន៍លើគ្រប់វិស័យធ្វើឱ្យខេត្តមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ព្រមទាំងបានខិតខំប្រមូលថវិកាជាតិបានយ៉ាងល្អប្រសើរ ក្នុងការរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើនឡើង។ ទន្ទឹមនឹងនេះគណៈប្រតិភូក្ដាប់បានព័ត៌មានអំពីការងាយស្រួល ការលំបាក បញ្ហាប្រឈម និងទិសដៅការងារបន្តរបស់អង្គភាពប្រមូលចំណូល ក្ដាប់បានអំពីនីតិវិធីនៃការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ និងការបន្តអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព ក្ដាប់បានវឌ្ឍនភាពនៃការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅមូលដ្ឋាន។ ដោយឡែកចំពោះសំណូមពរដែលអាជ្ញាខេត្ត និងមន្ទីរពាក់ព័ន្ធបានលើកឡើង គណៈកម្មការនឹងធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ផ្ដល់អនុសាសន៍ជូនក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីកែលម្អចំណុចសេសសល់។

ក្រៅពីនេះ គណៈប្រតិភូគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញទស្សនកិច្ចមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប ព្រមទាំងទស្សនកិច្ចស្ថានីយបុរាណបារាយណ៍អណ្ដែត ដែលជាទីសក្ការបូជា នៅសង្កាត់បារាយណ៍ ក្រុងព្រៃវែង ខេត្តព្រៃវែង៕

(អត្ថបទ និងរូបភាព៖ គឹម សិទ្ធី)



*គណៈកម្មការទី២ព្រឹទ្ធសភា ថតរូបអនុស្សាវរីយជាមួយអាជ្ញាធរខេត្តព្រៃវែង*

# សាស្ត្រាចារ្យ និស្សិតសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តក្រចេះ ទស្សនកិច្ចសិក្សានៅព្រឹទ្ធសភា



*ឯកឧត្តម ម៉ែន ស៊ីផាន់ អញ្ជើញធ្វើបទបង្ហាញ*

នាព្រឹកថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ ព្រះសង្ឃ សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តក្រចេះ ចំនួន១០០អង្គ/នាក់ បាននិមន្ត-អញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់អំពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា ដែលធ្វើបទបង្ហាញដោយឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា ស្តីពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា និងលោក **សុខ សុជាតិ** ជំនួយការអគ្គលេខាធិការព្រឹទ្ធសភា ធ្វើបទបង្ហាញស្តីពី ដំណើរការនីតិកម្មរបស់ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

ក្នុងឱកាសនោះ ឯកឧត្តម **ម៉ែន-ស៊ីផាន់** បានជម្រាបអំពីប្រវត្តិ និងគោលបំណង នៃការបង្កើតព្រឹទ្ធសភា ដែលក្នុងនោះ គឺការបញ្ចប់វិបត្តិនយោបាយ លើកកម្ពស់ការបង្រួបបង្រួមផ្សះផ្សារជាតិ និងពង្រឹងស្ថិរភាពនយោបាយ។

ព្រឹទ្ធសភាកើតឡើងដោយសារការបោះឆ្នោតអសកលមិនចំពោះ ដែលសមាជិកព្រឹទ្ធសភាចំនួន២រូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ២រូបត្រូវបានជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដោយប្រៀប នឹងសមាជិកព្រឹទ្ធសភា៥៨រូបទៀត ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកលមិនចំពោះ។ អង្គបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គឺតំណាងរាស្ត្រ និងក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសក្នុងតំណែង។

ឯកឧត្តមបានបញ្ជាក់ទៀតថា ព្រឹទ្ធសភាមានអាណត្តិ៦ឆ្នាំ ហើយរហូតមកដល់ពេលនេះ ព្រឹទ្ធសភាបានឈានដល់នីតិកាលទី៤ ដែលមានគណៈកម្មការជំនាញចំនួន១០។ គណៈកម្មការនីមួយៗ មានតួនាទី ភារកិច្ចជាសេនាធិការឱ្យព្រឹទ្ធសភា ដើម្បីជួយជ្រោមជ្រែងព្រឹទ្ធសភាក្នុងការតាក់តែង និងប្រតិបត្តិច្បាប់ឱ្យកាន់តែប្រសើរឡើង។ ព្រឹទ្ធសភាមានមុខងារចំនួន៣ គឺ៖មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង។ ក្រៅពីមុខងារទាំង៣នេះ ព្រឹទ្ធសភាក៏បានចូលរួមចំណែកជំរុញការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការនៅក្នុងប្រទេសកម្ពុជា





*សាស្ត្រាចារ្យ និស្សិតសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តក្រចេះ ស្តាប់បទបង្ហាញ*



*សាស្ត្រាចារ្យ និស្សិតសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តក្រចេះ ស្តាប់បទបង្ហាញ*

ឱ្យកាន់តែល្អប្រសើរឡើង ក្នុងការចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងការគ្រប់គ្រងប្រទេសប្រកបដោយតម្លាភាព និងគណនេយ្យភាពយ៉ាងពិតប្រាកដ។

បន្ទាប់ពីស្តាប់បទបង្ហាញរួចមក ព្រះសង្ឃ សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តក្រចេះ បានអញ្ជើញទស្សនាសាលប្រជុំព្រឹទ្ធសភា បណ្ណាល័យព្រឹទ្ធសភា និងអគារប្រវត្តិសាស្ត្រនានានៅក្នុងបរិវេណព្រឹទ្ធសភា។

សូមបញ្ជាក់ថា វិមានព្រឹទ្ធសភា អតីតវិមានរដ្ឋចំការមន ដែលត្រូវបានផ្តួចផ្តើមគំនិតកសាងឡើងក្នុងទសវត្សរ៍ទី៥០ ដោយព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ។ វិមានរដ្ឋចំការមន គឺជាទីកន្លែងសម្រាប់ទទួលបដិសណ្ឋារកិច្ចប្រមុខរដ្ឋនៃបណ្តាប្រទេសនានា ជាកន្លែងធ្វើការងារ និងជាព្រះរាជដំណាក់របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះរាជដំណាក់របស់ព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** និងព្រះរាជដំណាក់របស់ព្រះរាជបុត្រី **នរោត្តម បុប្ផាទេវី**។ ក្រៅពីនេះ នៅក្នុងវិមានរដ្ឋចំការមនក៏មានសាលបដិសណ្ឋារកិច្ច សាលរៀបចំពិធីជប់លៀង អគារការិយាល័យ កន្លែងស្នាក់នៅរបស់ភ្ញៀវ និងរោងភាពយន្តផងដែរ។ បច្ចុប្បន្នវិមានរដ្ឋចំការមនគឺជាកន្លែងធ្វើការរបស់ស្ថាប័នកំពូលៗចំនួន៣ស្ថាប័ន គឺព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានអាសយដ្ឋាននៅតាមបណ្តោយមហាវិថីព្រះនរោត្តម ជាប់វិមាន៧មករា (គណបក្សប្រជាជនកម្ពុជា)៕

(រូបភាព៖ លោក គឹម សិទ្ធី អត្ថបទ៖ លោក វង់ សុជាតិ)





*ឯកឧត្តម ម៉ែន ស៊ីផាន់ ថតរូបអនុស្សាវរីយ៍ជាមួយសាស្ត្រាចារ្យ និស្សិតសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច*

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា

❋ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញប្រជុំជាមួយមន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការទី១ព្រឹទ្ធសភា និងមន្ត្រីការិយាល័យអមក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ដើម្បីពិនិត្យលើខ្លឹមសារ៖

-របាយការណ៍ចន្លោះសម័យប្រជុំព្រឹទ្ធសភា នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០២២។



-របាយការណ៍ចន្លោះសម័យប្រជុំព្រឹទ្ធសភា ការត្រៀមរៀបចំអនុវត្តន៍សកម្មភាពការងារសម្រាប់ឆមាសទី២ ឆ្នាំ ២០២២ របស់គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ព្រមទាំងសួរសុខទុក្ខអំពីស្ថានភាពសុខភាពរបស់មន្ត្រី និងក្រុមគ្រួសារ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា នាថ្ងៃទី២ ខែសីហា ឆ្នាំ ២០២២។

❋ឯកឧត្តម **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖



-ប្រជុំជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសាលប្រជុំពិសេស វិមានព្រឹទ្ធសភា នាថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២ ដើម្បីពិនិត្យ សិក្សាលើ៖

១.សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

២.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ៖

-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃតំបន់រដ្ឋបាលពិសេសម៉ាកាវ នៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ

-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋតួកគី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។



-ដឹកនាំកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីពិនិត្យ និងពិភាក្សាលើគម្រោងថវិកាឆ្នាំ ២០២៣ របស់ព្រឹទ្ធសភា មុននឹងជួបពិភាក្សាការងារជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសាលាសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា នាថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២។

-ប្រជុំតាមប្រព័ន្ធនិម្មិត (Zoom) ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តម **ខឹម វិសុទ្ធ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ ដើម្បីពិនិត្យពិភាក្សាលើគម្រោងថវិកាឆ្នាំ២០២៣ របស់



ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២។



❈នាថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន៤ នៅសាលប្រជុំគណៈកម្មការទី៤ ព្រឹទ្ធសភា។

❈ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំៈ

-គណៈកម្មការទី៦ព្រឹទ្ធសភា ដើម្បីចាត់ឱ្យឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការសហការជាមួយនឹងលេខាធិការអមគណៈកម្មការនីតិកម្ម និងយុត្តិធម៌ ទទួលពិនិត្យសិក្សាស្រាវជ្រាវលើសេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ថ្មី(មួយ) មាត្រា៨៩ មាត្រា៩៨ថ្មី មាត្រា១០២ថ្មី មាត្រា១១៩ថ្មី(មួយ) និងមាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ថ្មី និងមាត្រា៤ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ នៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធសភា នារសៀលថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២។

-ក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) នៅសាលប្រជុំ



គណៈកម្មការទី៦ព្រឹទ្ធសភា នាថ្ងៃទី១ ខែសីហា ឆ្នាំ២០២២ ដើម្បីពិនិត្យពិភាក្សាត្រៀមមានមតិយោបល់ក្នុងសម័យប្រជុំព្រឹទ្ធសភា លើសេចក្តីព្រាងច្បាប់ចំនួន៤ រួមមានៈ

១-សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា១៩ថ្មី(មួយ) មាត្រា៨៩ មាត្រា៩៨ថ្មី មាត្រា១០២ថ្មី មាត្រា១១៩ថ្មី(មួយ) និងមាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ថ្មី និងមាត្រា៤ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ។

២-សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

៣-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើៈ

-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃតំបន់សេដ្ឋកិច្ចពិសេសម៉ាកាវ នៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ។

-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋតួកគី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាស្តីពីជំនួយក្នុងករណីមានគ្រោះមហន្តរាយនុយក្លេអ៊ែរ ឬគ្រោះអាសន្នវិទ្យុសកម្ម។

-គណៈកម្មការទី៦ព្រឹទ្ធសភា ដើម្បីពិនិត្យ សិក្សាលើ

សេចក្ដីព្រាងច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្មមាត្រា១៩ថ្មី (មួយ) មាត្រា៨៩ មាត្រា៩៨ថ្មី មាត្រា១០២ថ្មី មាត្រា១១៩ ថ្មី(មួយ) និងមាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ថ្មី និងមាត្រា៤ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ នៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធសភា នាថ្ងៃទី២ ខែសីហា ឆ្នាំ២០២២។



-បើកទូលាយរវាងគណៈកម្មការទី៦ព្រឹទ្ធសភាជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ធម្មនុញ្ញស្ដីពី វិសោធនកម្មមាត្រា១៩ថ្មី(មួយ) មាត្រា៨៩ មាត្រា៩៨ថ្មី មាត្រា១០២ថ្មី មាត្រា១១៩ថ្មី (មួយ) និងមាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ថ្មី និងមាត្រា៤ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ នៅសាលសិក្ខាសាលាបណ្ណាល័យ វិមានព្រឹទ្ធសភា នាថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២។

❋ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ដឹកនាំកិច្ចប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាលើឯកសារស្ដីពី តួនាទីសភាក្នុងការងារប្រែប្រួលអាកាសធាតុ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២។

❋ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំ៖

-គណៈកម្មការទី៩ព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាស្ដីពី ជំនួយក្នុងករណីមានគ្រោះមហន្តរាយនុយក្លេអ៊ែរ ឬគ្រោះអាសន្នវិទ្យុសកម្ម នៅសាលប្រជុំគណៈកម្មការទី៩ព្រឹទ្ធសភា នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២។



-ជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាស្ដីពី ជំនួយក្នុងករណីមានគ្រោះមហន្តរាយនុយក្លេអ៊ែរ ឬគ្រោះអាសន្នវិទ្យុសកម្ម នៅសាលប្រជុំពិសេសព្រឹទ្ធសភា នាថ្ងៃទី១ ខែសីហា ឆ្នាំ២០២២។

-គណៈកម្មការទី៩ព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សា និងឱ្យយោបល់ជាលើកចុងក្រោយលើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាស្ដីពី ជំនួយក្នុងករណីមានគ្រោះមហន្តរាយនុយក្លេអ៊ែរ ឬគ្រោះអាសន្នវិទ្យុសកម្ម នៅសាលប្រជុំពិសេសព្រឹទ្ធសភា នាថ្ងៃទី១ ខែសីហា ឆ្នាំ២០២២។

-ក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា នាថ្ងៃទី២ ខែសីហា ឆ្នាំ ២០២២ ដើម្បីពិនិត្យពិភាក្សា និងត្រៀមឱ្យយោបល់លើសេចក្ដីព្រាងច្បាប់៖



១-ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា១៩ ថ្មី(មួយ) មាត្រា ៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី (មួយ) និងមាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មីនៃច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ។

២-ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

៣-ស្តីពីការអនុម័តយល់ព្រមលើ៖

១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃតំបន់រដ្ឋបាលពិសេសម៉ាកាវ នៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ

២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋតួកគី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

៤-ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាស្តីពី ជំនួយក្នុងករណីមានគ្រោះមហន្តរាយនុយក្លេអ៊ែរ ឬគ្រោះអាសន្នវិទ្យុសកម្ម។



❈នាព្រឹកថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យលើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងារប្រចាំខែសីហា ឆ្នាំ២០២២ និងការត្រៀមជួបពិភាក្សាផ្លាស់ប្តូរបទពិសោធន៍ជាមួយគណៈកម្មាធិការស៊ើបអង្កេតអំពើពុករលួយ ការប្រព្រឹត្តខុស និងពង្រឹងអភិបាលកិច្ចល្អនៃព្រឹទ្ធសភាព្រះរាជាណាចក្រថៃឡង់ដ៍ នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា៕

## ការទទួលពាក្យបណ្តឹង

❈នៅខែសីហា ឆ្នាំ២០២២ ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន៦ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន១០ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធបានចំនួន១ករណី កំពុងពិនិត្យសិក្សាចំនួន៥ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន១០ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន១០ករណី តម្កល់ទុកមិនចាត់ការចំនួន១ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងចម្លងជូនគណៈកម្មការនានារបស់ព្រឹទ្ធសភាចំនួន៦ករណី៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

❈នាថ្ងៃទី១០ និងថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋឥណ្ឌា ក្នុងឱកាសខួប៧០ឆ្នាំ នៃមិត្តភាពកម្ពុជា-ឥណ្ឌា និងខួប៣០ឆ្នាំ នៃមិត្តភាពអាស៊ាន-ឥណ្ឌា នៅសាធារណរដ្ឋឥណ្ឌា៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្ដាភូមិភាគទាំង៨

❈ឯកឧត្តម **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមពិធីបុណ្យសពលោក **សុខ ឌីណា** នៅភូមិសន្សំកុសលទី១ សង្កាត់បឹងទំពុនទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ នាថ្ងៃទី២ ខែសីហា ឆ្នាំ២០២២។



-នាំយកទៀនព្រះវស្សា និងទេយ្យវត្ថុថ្វាយព្រះអង្គចេក-ព្រះអង្គចម នៅខេត្តសៀមរាប ដើម្បីបួងសួងសុំសេចក្ដីសុខ និងសន្តិភាព នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់ប្រជាពលរដ្ឋកំពុងដាំបន្លែបង្ការ នៅភូមិខ្សាំ ឃុំបន្ទាយដែក ស្រុកគៀនស្វាយ ខេត្តកណ្ដាល នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់កម្មករ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលទំនប់ទឹក ចម្ការដើមឈើក្រញូង និងហេដ្ឋារចនាសម្ព័ន្ធនានា នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខកម្មករ និងប្រជាពលរដ្ឋដែលអញ្ជើញមកសម្រាកកម្សាន្ត ព្រមទាំងទស្សនាសួនសត្វតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ម៉ុង ឫទ្ធី សែនជ័យ ព្រមទាំងចុះពិនិត្យមើលប្រព័ន្ធប្រឡាយទឹកបង្ហូរលូ និងហេដ្ឋារចនាសម្ព័ន្ធនានា នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០២២។



-ដឹកនាំក្រុមអ្នកបច្ចេកទេស បុគ្គលិក កម្មករផ្នែកកសិកម្ម ដឹកកូនដើមឈើធ្នង់ និងកូនដើមឈើបេងចំនួន៣.២២០ ដើម យកទៅដាំឡើងវិញ នៅតំបន់សួនសត្វភ្នំតាម៉ៅ ស្រុកបាទី ខេត្តតាកែវ នាថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលសហចេតិយ ប្រាសាទព្រះវិហារ ទំនប់ទឹក ចម្ការដើមឈើក្រញូង និងហេដ្ឋារចនាសម្ព័ន្ធនានា នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២។



-ដឹកកូនដើមឈើប្រណិតប្រភេទឈើបេង និងឈើធ្នង់ សម្រាប់យកមកដាំឡើងវិញនៅតំបន់ភ្នំតាម៉ៅចំនួន៣៣.១៣០ដើម ស្ថិតក្នុងតំបន់សួនសត្វភ្នំតាម៉ៅ ស្រុកបាទី ខេត្តតាកែវ នាថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២។

❈នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញ

ចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់ខេត្តព្រៃវែងប្រចាំខែកក្កដា និងលើកទិសដៅការងារខែសីហា ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលាខេត្តព្រៃវែង។

❈នាថ្ងៃទី១ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ អំពីតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

❈ឯកឧត្តម **ម៉ុម ជីមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល សួរសុខទុក្ខក្រុមប្រឹក្សាសង្កាត់ស្មៀន និងប្រជាពលរដ្ឋ នៅសាលាសង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ ដើម្បីស្ដាប់របាយការណ៍រួមក្នុងមូលដ្ឋាន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន ។



-ជួបសំណេះសំណាល សួរសុខទុក្ខក្រុមប្រឹក្សាសង្កាត់ស្មៀន និងប្រជាពលរដ្ឋ នៅសាលាសង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ នាថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២ ដើម្បីស្ដាប់របាយការណ៍រួមក្នុងមូលដ្ឋាន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន។

-ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាសង្កាត់ ស្មៀន



និងនគរបាលប៉ុស្ដិ៍រដ្ឋបាល សង្កាត់ភ្លើងឆេះរទេះ ខណ្ឌកំបូល រាជធានីភ្នំពេញ នាថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ដើម្បីស្ដាប់របាយការណ៍រួមក្នុងមូលដ្ឋាន ព្រមទាំងជួបជាមួយនឹងគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ នៅសាលបឋមសិក្សាភ្លើងឆេះរទេះ និងឧបត្ថម្ភថវិកាមួយចំនួន។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់ និងស្មៀន នៅសាលាសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ ដើម្បីស្ដាប់របាយការណ៍រួមក្នុងមូលដ្ឋាន ព្រមទាំងចុះពិនិត្យមើលការងារអភិវឌ្ឍមូលដ្ឋាន ដោយបានរៀបចំដាក់ប្រព័ន្ធលូរំដោះទឹកមួយខ្សែ ដើម្បីរំដោះទឹកស្អុយ និងរំដោះទឹកភ្លៀង ជូនបងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងឧបត្ថម្ភនូវថវិកាមួយចំនួន។

❈នាព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងចែកអំណោយជូនប្រជាពលរដ្ឋរស់នៅនៅតំបន់អង្គរ ខេត្តសៀមរាប។

❈ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមសិក្ខាសាលាបូកសរុបលទ្ធផល នៃការចូលរួមរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ អាណត្តិទី៥ ឆ្នាំ២០២២ និងការងារឆ្ពោះទៅកាន់ការរៀបចំបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នៅក្រុងតាខ្មៅ ខេត្តកណ្ដាល នាព្រឹកថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២។



-នាំយកអំណោយដ៏ថ្លៃថ្លារបស់ សម្តេចប្រធានព្រឹទ្ធសភា និងលោកជំទាវ មានដូចជា៖ ម៉ាស៊ីនពិនិត្យសម្ពាធបេះដូង ចំនួន១គ្រឿង ម្សៅទឹកដោះគោសម្រាប់ទារក និងកុមារចំនួន ៥.៤៧២កំប៉ុង ជូនដល់មន្ទីរពេទ្យជ័យវរ្ម័នទី៧ តាមរយៈ លោកសាស្ត្រាចារ្យមហាបរិញ្ញាវេជ្ជបណ្ឌិត **យ៉ៃ ចន្ថនា** ប្រធានមន្ទីរពេទ្យជ័យវរ្ម័នទី៧ និងនាំយកថវិកាមួយចំនួន ទៀតចែកជូនដល់ឪពុក ម្តាយរបស់ទារក និងកុមារដែល កំពុងសម្រាកព្យាបាលជំងឺក្នុងមន្ទីរពេទ្យ នៅក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២។

❋ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការ ទី១ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលសួរសុខទុក្ខក្រុមប្រឹក្សាឃុំ នៅឃុំ តាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី៦ ខែសីហា ឆ្នាំ ២០២២។



-ប្រគេនទេយ្យវត្ថុដល់ព្រះសង្ឃដែលកំពុងគង់ចាំព្រះ-វស្សាចំនួន៣វត្ត គឺះវត្តអង្គជុំមានលក្ខណ៍ (ហៅវត្តបាខុង) វត្តចំប៉ាលើក និងវត្តអង្គប្រសើ ស្ថិតក្នុងឃុំតាភេម ស្រុក ត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២។

❋នាថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ ជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំ ខែកក្កដា និងលើកទិសដៅការងារបន្តរបស់ស្រុកពាមជរ នៅសាលាស្រុកពាមជរ ខេត្តព្រៃវែង។

❋នាថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ម៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញ ចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់ខេត្ត បាត់ដំបងប្រចាំខែកក្កដា និងលើកទិសដៅការងារខែសីហា ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេច ក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ នៅសាលមហោស្រពស្ទឹងសង្កែ ខេត្តបាត់ដំបង។

❋ឯកឧត្តម **អាយ ខន** អនុប្រធានគណៈកម្មការ ទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅក្នុងស្រុកបុទុមសាគរ ខេត្តកោះកុង នា ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងការពង្រឹងតួនាទី ភារកិច្ចរបស់ ក្រុមប្រឹក្សាឃុំអាណត្តិទី៥ និងការផ្តល់សេវាសាធារណៈ របស់មន្ត្រីនៅមូលដ្ឋាន នៅស្រុកមណ្ឌលសីមា ខេត្តកោះកុង នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០២២។

❋ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការ ទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល សួរសុខទុក្ខ មន្ត្រីលេខាធិការ-ដ្ឋាន មន្ត្រីផ្នែកអនាម័យ និងផ្នែកសន្តិសុខ ដោយបានផ្តាំ-ផ្ញើឱ្យបន្តខិតខំបំពេញការងារ ថែរក្សាសុខភាព ដើម្បីរួម គ្នាប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងបានឧបត្ថម្ភកន្សែង ពោះគោ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា នាព្រឹក ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២។



-ចូលរួមប្រជុំការងារជាមួយនឹងក្រុមប្រឹក្សាសង្កាត់ទឹក-

ល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ អាណត្តិទី៥ ព្រមទាំងឧបត្ថម្ភនូវសម្ភារការងាររដ្ឋបាលមួយចំនួន នារសៀលថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២។



-ចុះសួរសុខទុក្ខលោក **សេង សាវ៉ាន់** អតីតប្រធានក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលកំពុងសម្រាកព្យាបាល និងថែទាំសុខភាពនៅគេហដ្ឋាន ព្រមទាំងឧបត្ថម្ភអង្ករ កន្សែងពោះគោ សាប៊ូ ទឹកបរិសុទ្ធ និងថវិកាមួយចំនួន នាថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ព្រមទាំងសួរសុខទុក្ខលោកស្រី **ឌិត្យ សំអូន** អតីតចៅសង្កាត់ នៅគេហដ្ឋាន ដោយបានជួយឧបត្ថម្ភអង្ករ ត្រីខ កន្សែងពោះគោ សាប៊ូ ទឹកអាកុល ម៉ាស់ និងថវិកាមួយចំនួន នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២។



❋នាថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងពិនិត្យទីតាំងសាងសង់ផ្លូវមួយខ្សែធ្វើពីបេតុងប្រវែង១.០០០ម៉ែត្រ នៅភូមិពងទឹក ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល នាព្រឹកថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២។



-ជួបសំណេះសំណាល និងប្រគល់ថវិកាមួយចំនួន ដើម្បីសាងសង់ផ្លូវមួយខ្សែធ្វើពីបេតុងប្រវែង១.០០០ម៉ែត្រ នៅភូមិពងទឹក ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល នាព្រឹកថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២។

❋នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំបូកសរុបលទ្ធផលការងារ និងលើកទិសដៅការងារបន្តរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ព្រមទាំងជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។

❋នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញដង្ហែទៀនព្រះវស្សា និងនាំយកបច្ច័យ កសាងទ្វារសាលាឆាន់ ទៅវេរប្រគេនព្រះសង្ឃគង់នៅវត្តអង្គសិម្ពលី ស្ថិតនៅឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល។

❋នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **គិន ណៃត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញនាំយកទៀនព្រះវស្សាទៅប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាចំនួន ៣វត្តគឺ៖ វត្តកោះអណ្ដែត វត្តអង្គប្រាសាទ (ធម្មយុត) និងវត្តពោធិ៍នាគរាជ ស្ថិតក្នុងឃុំរមេញ ស្រុកកោះអណ្ដែត ខេត្តតាកែវ។

❋នាថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ឈាំ ទុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភាអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្ដិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ នៅក្រុងប៉ៃលិន ខេត្តប៉ៃលិន។

❋នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **អន**



**ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ២០២២ និងពិធីដុតបំផ្លាញវត្ថុតាងគ្រឿងញៀន ក្រោមប្រធានបទ "ដោះស្រាយបញ្ហាគ្រឿងញៀនក្នុងវិបត្តិសុខភាព និងមនុស្សធម៌" ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅសាកលវិទ្យាល័យជាតិមានជ័យ ខេត្តបន្ទាយមានជ័យ។

❈ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបុណ្យ៖

-សពមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភ **ដុក ខែន** ត្រូវជាម្តាយក្មេកឯកឧត្តមនាយឧត្តមសេនីយ៍ **វៀង អំ** រដ្ឋលេខាធិការក្រសួងការពារជាតិ ស្ថិតនៅឃុំពងទឹក ស្រុករំដួល ខេត្តស្វាយរៀង នាថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២។

-ឆ្លងផ្លូវថ្នល់ និងចុះមើលសិប្បកម្មផលិតក្រមា និងទំនប់ទឹកស្វាយយា ក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២។

❈នាថ្ងៃទី៣០ និងថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលដកពិសោធន៍ការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ និងផ្សព្វផ្សាយលទ្ធផលការងារអនុវត្តកន្លងមក ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅសាលប្រជុំសាលាខេត្ត ខេត្តបន្ទាយមានជ័យ។

❈នាព្រឹកថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២ លោកជំទាវ **មុំ សណ្តាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់



និងមន្ត្រីរដ្ឋបាលខណ្ឌដង្កោ ព្រមទាំងនាំយកអំណោយមួយចំនួនជូនលោកស្រី **ទិត្យ សំអុន** អតីតចៅសង្កាត់សាក់សំពៅ នៅគេហដ្ឋានស្ថិតក្នុងសង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

❈នារសៀលថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញនាំយកទេយ្យវត្ថុ និងថវិកាទៅប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សានៅវត្តមួង ឃុំមួងរៀវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

❈ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖



-សហការជាមួយនឹងក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភាអញ្ជើញចុះពិនិត្យជំងឺទូទៅជូនប្រជាពលរដ្ឋក្នុងស្រុកអូររាំងឪ ដោយឥតគិតថ្លៃ ពីថ្ងៃទី១០ ដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ នៅវត្តបន្ទាយមៀន ឃុំមៀន ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។



-ជួបសំណេះសំណាល និងថ្លែងអំណរគុណដល់ក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ឆេង ខន** អនុប្រធានទី២ព្រឹទ្ធសភា និងក្រុមគ្រូពេទ្យស្ម័គ្រចិត្តប្រទេសបារាំងដែលបានមកពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយមិនគិតថ្លៃ ស្ថិតនៅវត្តបន្ទាយមៀន ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២។

❈នាថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ឌឹម លាច** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ស្មៀនឃុំ មេប៉ុស្តិ៍ឃុំ និងគណៈភូមិទាំង១០នៃឃុំត្រពាំងគរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

❈នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ញ៉ែប សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញនាំយកចង្ហាន់បិណ្ឌបាត ព្រមទាំងបរិក្ខារ និងបច្ច័យមួយចំនួនទៅប្រគេនជូនព្រះពោធិវង្សាវិមលព្រះមេគណខេត្ត និងព្រះសង្ឃដែលគង់ចាំព្រះវស្សានៅក្នុងវត្តកែវវិជ័យ ក្នុងស្រុកកណ្តៀង ខេត្តពោធិ៍សាត់។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខថ្នាក់ដឹកនាំព្រះវិហារ និងប្រជាពលរដ្ឋចាស់ជរាដែលមានជំងឺចំនួន៤នាក់ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនដល់ពួកគាត់ នៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប នារសៀលថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខថ្នាក់ដឹកនាំព្រះវិហារត្រពាំងស្នាច់ ដែលកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យស្តង់ដារកំពត ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន នៅភូមិបឹងតារោង ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋកំពុងប្រកបមុខរបរដាំដំណាំផ្សេងៗ នៅឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២។

❈នាថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងលោកគ្រូ អ្នកគ្រូ នៅសាលាបឋមសិក្សាព្រះឥន្ទកោសីយ៍ ចំនួន៣១នាក់ និងឧបត្ថម្ភថវិកាមួយចំនួនសម្រាប់សាងសង់អគារមត្តេយ្យសិក្សា នៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។



❈នាថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ម្លូខ ម៉ីយ** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំសង្កាត់ និងប្រជាពលរដ្ឋនៅឃុំតាវែងក្រោម ស្រុកតាវែង ខេត្តរតនគិរី។



❈នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២ លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងពិធីសំណេះសំណាល និងដាំកូនដើមឈើចំនួន៥០០ដើម ព្រមទាំងប្រគេនបច្ច័យមួយចំនួនដល់ព្រះគ្រូចៅអធិការវត្ត និងជូនក្រមាដល់លោកយាយលោកតា និងថវិកាមួយចំនួនដល់ប្រជាការពារ នៅវត្តឥន្ទកុមារ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

❈នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ គន់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបញ្ចុះបឋមសិលាសាងសង់អគារសិក្សា១ខ្នងកម្ពស់៤ជាន់ មាន២០បន្ទប់ ក្នុងបរិវេណអនុវិទ្យាល័យសោហី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅខេត្តបាត់ដំបង។

❈នាថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ស្រី ថេន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញសំណេះសំណាលជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ។

❋ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីផ្សព្វផ្សាយខ្លឹមសារសំខាន់ៗនៃកម្មវិធីនយោបាយអភិវឌ្ឍឃុំ ជូនដល់ក្រុមប្រឹក្សាឃុំ យុវជន និងប្រជាពលរដ្ឋ សរុបចំនួន១២០នាក់ នៅសាលាស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់សាលាឃុំសម្រាប់តម្រូវការចាំបាច់និងការសាងសង់ស្ពានមួយកន្លែង នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២២។



-នាំយកបរិក្ខារបច្ច័យ៤ និងចង្ហាន់ ទៅប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាអស់កាលត្រីមាស នៅវត្តព្រះព្រហ្មរតន៍ និងវត្តពោធិបន្ទាយជ័យ ស្ថិតនៅក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំព្រះប្រឡាយ ឃុំទំនប់ដាច់ ឃុំបាក់អន្លូង និងនគរបាលប៉ុស្តិ៍រដ្ឋបាលស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដើម្បីឈ្វេងយល់អំពីការងារបម្រើសេវាជូនប្រជាពលរដ្ឋ ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការងារអត្រានុកូលដ្ឋាន ការងារភូមិ ឃុំ មានសុវត្ថិភាព ព្រមទាំងឧបត្ថម្ភម៉ាស់ សៀវភៅ និងថវិកាមួយចំនួន នាថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២។

-ចូលរួមពិធីបុណ្យទក្ខិណានុប្បទានគម្រប់ប្រាំពីរថ្ងៃសពប្រពន្ធលោក **ខាន់ ខែម** មេឃុំត្រពាំងប្រាសាទ និងសួរសុខទុក្ខលោក **ខាន់ ខែម** កំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋានស្ថិតក្នុងឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នារសៀលថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២។

❋ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងពិធីផ្សព្វផ្សាយខ្លឹមសារសំខាន់ៗ និងបទពិសោធន៍ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ជូនដល់ក្រុមប្រឹក្សាស្រុក ឃុំ ថ្នាក់ភូមិ នាយប៉ុស្តិ៍នគរបាលរដ្ឋបាល នាយកវិទ្យាល័យ នាយកអនុវិទ្យាល័យ និងសាលាបឋមសិក្សា សរុបចំនួន ១៨២នាក់ នៅសាលាស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំព្រៃគ្រី ដើម្បីស្ដាប់របាយការណ៍រួមក្នុងមូលដ្ឋាន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់មណ្ឌលសុខភាពព្រៃគ្រី និងសាលាបឋមសិក្សាព្រៃគ្រីត្បូង នៅឃុំព្រៃគ្រី ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នារសៀលថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២។



-គោរពវិញ្ញាណក្ខន្ធសពលោកជំទាវ **ឈុំ ច័ន្ទសុខ** សមាជិកក្រុមប្រឹក្សាខេត្ត នៅគេហដ្ឋានសព ភូមិឡទឹកត្រី ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីប្រារព្ធទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០២២ ក្រោមប្រធានបទ "ទាំងអស់គ្នារួមជាមួយកាកបាទក្រហមកម្ពុជា ដោះស្រាយបញ្ហាប្រឈម និងបន្តពង្រឹងភាពធន់សហគមន៍" ក្រោមអធិបតីភាពលោកជំទាវ **ពុំ ចន្ទីនី** អគ្គលេខាធិការកាក-

បាទក្រហមកម្ពុជា នៅសាលាខេត្តកំពង់ឆ្នាំង នាថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២។



-ជួបសំណេះសំណាល សួរសុខទុក្ខក្រុមប្រឹក្សាឃុំកោះ-ថ្កូវ ស្មៀនឃុំ ប្រធានប៉ុស្តិ៍រដ្ឋបាលឃុំ និងប្រធានភូមិទាំង ១០ ដើម្បីស្ដាប់របាយការណ៍រួមក្នុងមូលដ្ឋាន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់អ្នកចូលរួម និងសម្រាប់មូលនិធិ-សង្គហធម៌ឃុំ នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២។

❈ឯកឧត្ដម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលសួរសុខទុក្ខក្រុមប្រឹក្សាសង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានភូមិក្នុងសង្កាត់ព្រៃធំ និងសង្កាត់កែប ស្ថិតក្នុងក្រុងកែប ខេត្តកែប នាព្រឹកថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២។



-ជួបសំណេះសំណាលសួរសុខទុក្ខក្រុមប្រឹក្សាសង្កាត់អូរក្រសារ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងប្រធានភូមិក្នុងសង្កាត់អូរក្រសារ នៅសាលាសង្កាត់អូរក្រសារ ក្រុងកែប ខេត្តកែប នាព្រឹកថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំពងទឹក ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានមណ្ឌល-សុខភាពឃុំ ប្រធានភូមិក្នុងឃុំពងទឹក និងប្រធានភូមិក្នុងឃុំអង្កោល នៅស្រុកដំណាក់ចង្អើរ ខេត្តកែប នាថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខ និងប្រគល់ផ្ទះ១ខ្នង រួមទាំងសូឡាបំភ្លឺ៣គ្រឿង គ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួន ដែលជាអំណោយរបស់សប្បុរសជនតាមរយៈសមាគមរាជសីហ៍សាខាខេត្តកំពត ជូនដល់ស្រីមេម៉ាយឈ្មោះ **ណុប លី** ដែលកំពុងមានជំងឺប្រចាំកាយ រស់នៅជាមួយចៅកំព្រាម្នាក់ ស្ថិតក្នុងភូមិត្រពាំងនៀល ឃុំឫស្សី-ស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត នាសៀលថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២២។

❈នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២ ឯកឧត្ដម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់ស្រុកអង្គរធំប្រចាំខែសីហា ឆ្នាំ២០២២ និងលើកទិសដៅការងារបន្ត នៅស្រុកអង្គរធំ ខេត្តសៀមរាប។

❈លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈ-កម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមពិធីបុណ្យរុក្ខទិវា ៩ កក្កដា ឆ្នាំ២០២២ ដែលរៀបចំឡើងដោយរដ្ឋបាលស្រុកបាសាទបាគង នៅភូមិរលួសខាងលិច ឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀម-រាប នាព្រឹកថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២។

-ជាគណៈអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែសីហា និងលើកទិសដៅការងារបន្តរបស់រដ្ឋបាលស្រុកប្រាសាទបាគង ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនអង្គពិធី នៅខេត្តសៀមរាប នាព្រឹកថ្ងៃទី៧ ខែសីហា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងលោកគ្រូ អ្នកគ្រូ នៅសាលាបឋមសិក្សាព្រះឥន្ទកោសីយ៍ ស្ថិតនៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២។

-នាំយកថវិកាមួយចំនួន ដើម្បីឧបត្ថម្ភដល់វិទ្យាល័យចៅស្រីវិបុលកេត្ត ក្នុងការតអគ្គិសនីចូលក្នុងសាលារៀន ស្ថិតនៅភូមិត្រាច ឃុំបល្ល័ង្គ ស្រុកប្រាសាទបាគង ខេត្តសៀមរាប នាព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ

❈នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ សមាជិក សមាជិកាព្រឹទ្ធសភាចំនួន២០រូប អញ្ជើញចូលរួមជាកិត្តិយសក្នុងសិក្ខាសាលាស្ដីពី “ការស្វែងយល់អំពីការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់រៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣” ក្រោមអធិបតីភាពឯកឧត្ដមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១នៃរដ្ឋសភា នៅវិមានរដ្ឋសភា។

❈ឯកឧត្ដមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបុណ្យ៖

-សពឧបាសិកា **តាំង អៀង** នៅគេហដ្ឋានសព នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២។

-សពឧបាសិកា **ហម ធារី** នៅឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២។

❈នាថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ ឯកឧត្ដម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីគម្រប់ខួបលើកទី៥៧ នៃបុណ្យជាតិសិង្ហបុរី នៅសណ្ឋាគារ Raffle le Royal រាជធានីភ្នំពេញ។

❈នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២ ឯកឧត្ដម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្ដម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីគម្រប់ខួបលើកទី៧៥ នៃបុណ្យឯករាជ្យជាតិឥណ្ឌា នៅសណ្ឋាគារ Hyatt Regency រាជធានីភ្នំពេញ។



❈នារសៀលថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសពិធីអបអរសាទរខួបអនុស្សាវរីយលើកទី៥៥ ថ្ងៃបង្កើតទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម (២៤ មិថុនា ឆ្នាំ១៩៦៧ - ២៤ មិថុនា ឆ្នាំ២០២២) ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងជាប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ និងលោកជំទាវ **ហា ធីថ៉ា** សមាជិកាគណៈកម្មាធិការកណ្ដាលគណបក្សកុម្មុយនីស្ដ ជាសមាជិការដ្ឋសភា និងជាប្រធានសហព័ន្ធនារីវៀតណាម នៅសណ្ឋាគារ Hyatt Regency រាជធានីភ្នំពេញ។



❈នាថ្ងៃទី២៦ ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញអមដំណើរគណៈប្រតិភូសហព័ន្ធនារីវៀតណាម ដឹកនាំដោយលោកជំទាវ **ហា ធីថ៉ា** សមាជិកាគណៈកម្មាធិការកណ្ដាលគណបក្សកុម្មុយនីស្ដ សមាជិការដ្ឋសភា និងជាប្រធានសហព័ន្ធនារីវៀតណាម ទៅទស្សនកិច្ចនៅខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែប។



❋នាថ្ងៃទី១០ និងថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា និងឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពី តួនាទីសភាក្នុងការលើកកម្ពស់ការឆ្លើយតបប្រកបដោយបរិយាបន្ន និងចីរភាព ចំពោះគ្រាអាសន្នសុខាភិបាល ករណីសិក្សាពីប្រសិទ្ធភាព និងឧបសគ្គនៃការឆ្លើយតបថ្នាក់ជាតិចំពោះជំងឺកូវីដ-១៩ នៅសណ្ឋាគារ Royal Angkor Resort and Spa ខេត្តសៀមរាប។




❋នាថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញដឹកនាំគណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភាគោរពវិញ្ញាណក្ខន្ធសពមហាវីរិយាភិរក្ខសិរីអគ្គមហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ **ខេវ៉ូ ស៊ីនស្រេង** ឪពុកបង្កើតរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** នៅគេហដ្ឋានលេខ១៧ ផ្លូវលេខ៦០៤ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

❋ឯកឧត្តម **ម៉ម ម៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖



-ទទួលបដិសណ្ឋារកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះគណៈប្រតិភូមូលនិធិចែករំលែកសង្គ្រោះជីវិតសកល (Global Life Sharing) នៃសាធារណរដ្ឋកូរ៉េ ដឹកនាំដោយលោក Kim Jung Nam ប្រធានមូលនិធិ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាថ្ងៃទី២ ខែសីហា ឆ្នាំ២០២២។



-រៀបចំពិធីជប់លៀងស្វាគមន៍គណៈប្រតិភូមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ដឹកនាំដោយលោក Kim Jung Nam ប្រធានមូលនិធិ ក្នុងឱកាសដែលគណៈប្រតិភូមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២។



-ចូលរួមក្នុងពិធីពិសាអាហារការងារ ដែលរៀបចំដោយគណៈប្រតិភូមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ដឹកនាំដោយលោក Kim Jung Nam ប្រធានមូលនិធិ ស្ថិតនៅរាជធានីភ្នំពេញ នាថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២។



-ជូនដំណើរគណៈប្រតិភូមូលនិធិចែករំលែកសង្គ្រោះ

ជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ដឹកនាំដោយលោក Kim Jung Nam ប្រធានមូលនិធិ ធ្វើដំណើរនិវត្តន៍ទៅកាន់មាតុប្រទេសវិញ បន្ទាប់ពីគណៈប្រតិភូបានអញ្ជើញមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី២ ដល់ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០២២។



-ជាកិត្តិយសក្នុងកិច្ចប្រជុំពិភាក្សាការងារជាមួយគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃរដ្ឋសភា ដឹកនាំដោយឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការ ដើម្បីត្រៀមទទួលជួបសំណេះសំណាលពិភាក្សាការងារជាមួយនឹងគណៈប្រតិភូព្រឹទ្ធសភាសហរដ្ឋអាមេរិក ដឹកនាំដោយឯកឧត្តម Edward J. Markey សមាជិកព្រឹទ្ធសភា ស្ថិតនៅសាលប្រជុំគណៈកម្មការទី៥រដ្ឋសភា នាព្រឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២។



-ចូលរួមកិច្ចប្រជុំពិភាក្សាការងាររវាងគណៈប្រតិភូគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃរដ្ឋសភា ដឹកនាំដោយឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការ និងជាអនុប្រធានក្រុមមិត្តភាពរដ្ឋសភាកម្ពុជា-អាមេរិក ជាមួយនឹងគណៈប្រតិភូព្រឹទ្ធសភាសហរដ្ឋអាមេរិក ដឹកនាំដោយឯកឧត្តម Edward J. Markey សមាជិកព្រឹទ្ធសភា ស្ថិតនៅសាលប្រជុំបាយ័ន នៃរដ្ឋសភា នាព្រឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២។

❋នារសៀលថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភា ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបុណ្យគម្រប់ខួប១០០ថ្ងៃ ឧទ្ទិសកុសលជូនចំពោះដួងវិញ្ញាណក្ខន្ធ សម្តេចឧត្តមទេពញាណ **ហ៊ុន ណេង** អតីតសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងជាអ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នៅខេត្តកំពង់ចាម។

❋ឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីបើកកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខាភ្នំពេញ នាថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២។

-ចូលរួមពិធីជប់លៀងជូនគណៈប្រតិភូចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធ ក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅសណ្ឋាគារសុខាភ្នំពេញ នាថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២។



❋នាថ្ងៃទី១៧ និងទី២៤ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជួបពិភាក្សាការងារជាមួយ Bernadette Bolo-Duthy តំណាងអង្គការលំនៅដ្ឋានមនុស្សជាតិប្រចាំ

នៅកម្ពុជា (Habital for Humanity Cambodia) ដើម្បីពិភាក្សាអំពីវឌ្ឍនភាពនៃសូចនាករសំខាន់ៗក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDG) នៅកម្ពុជា នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា។

❈នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ណារ៉ំ ធុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **ជឹម លាវ** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបុណ្យខួបគម្រប់១០០ថ្ងៃសព សម្ដេចឧត្ដមទេពញាណ **ហ៊ុន ណេង** សមាជិកគណៈ-កម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈនៃរដ្ឋសភា និងជាតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម នៅភូមិគ្រឹះលេខ ០០៩ ផ្លូវព្រះកេតុមាលា ភូមិទី៧ ក្រុងកំពង់ចាម ខេត្តកំពង់ចាម ។



❈នាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ លោកជំទាវ **ឃួន យុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ នៃគណៈកម្មា-ធិការស្ត្រីវ៉ាយប៉ា (WAIPA) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** ប្រធានគណៈ-កម្មាធិការស្ត្រីវ៉ាយប៉ា និងជាអនុប្រធានទី២រដ្ឋសភា នៅខុទ្ទកាល័យអនុប្រធានទី២រដ្ឋសភា។

❈នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ លោកជំទាវ **ឃួន យុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា លោកជំទាវ **ជា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់ ១០០ថ្ងៃ សម្ដេចឧត្ដមទេពញាណ **ហ៊ុន ណេង** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈនៃរដ្ឋសភា និងជាតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម នៅគេហដ្ឋាន ភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម។




❈នាថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ លោកជំទាវ **ជា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសពឧបាសិកាកុសលចិត្តាមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ពេន យុត** ម្ដាយក្មេករបស់ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន នៅភូមិគ្រឹះលេខ៣៨ ផ្លូវ២៨៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។




❈នាព្រឹកថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមជំនួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម **អ៊ុន ចាន់ដា** អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ព្រមទាំងបាននាំយកអំណោយមួយចំនួនរួមមាន ៖ អង្ករចំនួន២តោន មីចំនួន១០០កេស ត្រីខកំប៉ុងចំនួន១០០យួរ និងទឹកបរិសុទ្ធចំនួន១០០កេស ឧបត្ថម្ភជូនរដ្ឋបាលខេត្តកំពង់ចាម សម្រាប់ប្រើប្រាស់តាមការចាំបាច់នៅសាលាខេត្តកំពង់ចាម៕

# ឯកឧត្តម អ៊ុំ សារឹទ្ធ៖ បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ព្រឹទ្ធសភាលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែនទន់ភ្លន់ក្នុងសភាពការណ៍ចល័ត



ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការព្រឹទ្ធសភា

បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥របស់ព្រឹទ្ធសភា ក្នុងលក្ខណៈបត់បែនទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារ។ ការកំណត់ទិសដៅការងារបែបនេះ ត្រូវបានឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បញ្ជាក់ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែកក្កដា និងលើកទិសដៅការងារសម្រាប់ខែសីហា ឆ្នាំ២០២២ នាព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ២០២២ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចាប់ពីប្រធាននាយកដ្ឋានឡើង។

នៅក្នុងឱកាសនោះ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានជម្រាបជូនអង្គប្រជុំជ្រាបអំពីសភាពការណ៍អន្តរជាតិ តំបន់ និងសភាពការណ៍ជាតិ ព្រមទាំងធ្វើការបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងខែកក្កដាថា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបន្តបោះជំហានទៅមុខយ៉ាងស្វាហាប់ ដោយបានរៀបចំ និងចាត់ចែងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍បានយ៉ាងល្អប្រសើរ។ ជាពិសេសរិស្សមកាលរយៈពេល៣ខែរបស់ព្រឹទ្ធសភា នឹងឈានទៅបិទបញ្ចប់នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២ ខាងមុខ។ សមាជិក សមាជិកាព្រឹទ្ធសភា បានយកចិត្តទុកដាក់ធ្វើសកម្មភាពឆ្ពោះទៅកាន់មូលដ្ឋាន ដោយបានចុះបំពេញបេសកកម្មជួបសវនាការការងារជាមួយនឹងក្រសួង និងស្ថាប័ននានា ព្រមទាំងចុះប្រាស្រ័យទាក់ទងជាមួយនឹងប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋាន ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ព្រមទាំងផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ជាពិសេសណែនាំប្រជាពលរដ្ឋឱ្យទៅចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ (ដូសជំរុញ) ឱ្យបានគ្រប់ៗគ្នា នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា។

ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ អគ្គលេខា-





ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
ចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកក្កដា




*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកក្កដា*

ធិការដ្ឋានព្រឹទ្ធសភាបានរៀបចំ និងចាត់ចែងបានយ៉ាងល្អប្រសើរជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងជួបពិភាក្សាការងារជាមួយនឹងគណៈប្រតិភូអន្តរជាតិក្នុងការបង្កើនទំនាក់ទំនង ដើម្បីជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីបានកាន់តែល្អប្រសើរជាលំដាប់។

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានណែនាំដល់ថ្នាក់ដឹកនាំអង្គភាពចំណុះទាំងអស់ ឱ្យផ្សព្វផ្សាយដល់មន្ត្រីរាជការក្រោមឱវាទ ត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការនានា ដែលរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល បានដាក់ចេញ ជាពិសេសវិធានការ “៣ការពារ ៣កុំ” និងការចាក់វ៉ាក់សាំងដូសជំរុញឱ្យបានគ្រប់ៗគ្នាកុំបីខាន ដើម្បីការពារមិនឱ្យជំងឺកូវីដ-១៩ អាចឆ្លងរាលដាលជាថ្មីទៀតបាន។

សូមជម្រាបថា អង្គប្រជុំដំណើរការតាមកម្មវិធី ដោយមានការបញ្ចាំងវីដេអូបូកសរុបលទ្ធផលការងារប្រចាំខែកក្កដា និងទិសដៅការងារខែសីហា ឆ្នាំ២០២២ ព្រមទាំងកិច្ចពិភាក្សាផ្លាស់ប្តូរបទពិសោធន៍ការងារ បញ្ហាប្រឈម សំណូមពរ និងមតិបូកសរុបរបស់ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ គឹម សិទ្ធី)





*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកក្កដា*

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ




❈នាព្រឹកថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានដឹកកិច្ចប្រជុំត្រួត-ពិនិត្យ និងពិភាក្សាអំពីការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងធនធានមនុស្ស ដោយមានការអញ្ជើញចូលរួម ពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីប្រធាននាយកដ្ឋានឡើង នៅសាលសិក្ខាសាលា ខាងជើង វិមានព្រឹទ្ធសភា។





❈នាព្រឹកថ្ងៃទី២២ ដល់ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បាន អញ្ជើញជាអធិបតីភាពក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងធនធានមនុស្ស សម្រាប់ថ្នាក់ដឹកនាំអង្គភាពចាប់ពី អនុប្រធាននាយកដ្ឋានឡើង នៅសាលសិក្ខាសាលាបណ្ណាល័យ វិមានព្រឹទ្ធសភា។





❈នារសៀលថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញ ជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី “កិច្ចការសភា (ជំហានទី៥)” នៅសាលសិក្ខាសាលខាងជើងវិមាន ព្រឹទ្ធសភា។

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ






❋នារសៀលថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្ដុះបណ្ដាលស្ដីពី “ការស្រាវជ្រាវសភា” សម្រាប់មន្ត្រីសភាកម្ពុជា(ព្រឹទ្ធសភា និងរដ្ឋសភា) ដែលរៀបចំដោយមជ្ឈមណ្ឌលសភាអាស៊ី តាមប្រព័ន្ធនិម្មិត(ZOOM) នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។





❋នារសៀលថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ គណៈកម្មការត្រួតពិនិត្យ និងអង្គភាពបេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងពិភាក្សាអនុក្រឹត្យលេខ៖ ១៦២ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ ស្ដីពីការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងឧបត្ថម្ភអ្នកបម្រើការជូនជនពិការ និងជនបាត់បង់សមត្ថភាពការងារថ្នាក់ទី១ ក្រោមអធិបតីភាពលោកជំទាវ **រ័ត្ន ឆវីលក្ខណ៍** ប្រធានគណៈកម្មការត្រួតពិនិត្យ និងជាអគ្គាធិការ នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធសភា។





❋នារសៀលថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ បានចូលរួមរំលែកទុក្ខ និងអញ្ជើញគោរពវិញ្ញាណក្ខន្ធសពមហាវិរិយាភិរ័ក្ខសិរី អគ្គមហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ **ខេវ៉ូ ស៊ុនស្រេង** ឪពុកបង្កើតរបស់ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន នៅគេហដ្ឋានលេខ១៧ ផ្លូវលេខ៦០៤ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ៕

